OMI0005(1)

# មជ្ឈមណ្ឌលឯកសារកម្ពុជា

**សម្ភាសន៍ជាមួយ សំ ភីន ភេទប្រុស អាយុ៥៥ឆ្នាំ**

**មុខងារសម័យខ្មែរក្រហមៈ ប្រធានភស្តុភារប្រចាំកងពល១៦៤**

**សព្វថ្ងៃរស់នៅភូមិជើងភ្នំ ឃុំត្រពាំងប្រិយ៍ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ**

**ខែសីហា ឆ្នាំ២០១១**

**សម្ភាសន៍ដោយៈ ប៊ិន ម៉ូលីកា**

**០១:៣៣:១៥**

**៣៨ទំព័រ**

កា : កាលពីមុនអ៊ំអាចជួយរៀបរាប់បទពិសោធន៍ខ្លះ កាលពីមុនអ៊ំចូលសម័យសង្គ្រាម ហើយមកដល់សម័យសង្គ្រាមនឹងអ៊ំធ្វើអី បងប្អូនប៉ុន្មាននាក់ ។

ភីន : ហើយចៅឯងអត់ដែលធ្វើសង្គ្រាមទេចុះ?

កា : ខ្ញុំគ្មានដែលធ្វើសង្គ្រាមទេ (សើច) ។

ភីន : ធ្វើសង្គ្រាមយ៉ាប់ណាស់ ។

កា : យ៉ាប់ម៉េចខ្លះទៅ?

ភីន : មើលគម្រោងគេអី ពិបាកនិយាយណាស់ បើគេសួរឆ្លើយៗមកស្រួល ។

កា : ចឹងខ្ញុំសួរម៉ងចឹង ។

ភីន : អឺ! ឈ្មោះអ្នកធ្វើបទសម្ភាសន៍ ។

កា : ឈ្មោះខ្ញុំ ។

ភីន : ការបរិឆ្លេទ ។

កា : បើនេះអ៊ំបំពេញខ្លួនឯងទៅក៏បាន ។

ភីន : មិនទេចៅ ស្រួលទៅស្រួល ។

កា : អានេះសួរទាក់ទងពីអារម្មណ៍អ៊ំ ព្រោះអ្នកដែលឆ្លងពីសម័យអីចឹង ចង់ដឹងថា អាចមានអារម្មណ៍ ចង់ដឹងថាអាចមានអារម្មណ៍ភ័យខ្លាចអីអត់ ។

ភីន : ភ័យខ្លាចអី?

កា : ព្រោះអីអ្នកដែលចេញពីសម័យសង្គ្រាម អ្នកខ្លះតក់ស្លុតអីចឹង ។

ភីន : អូ! អ៊ំអត់ចេះតក់ស្លុតទេ ។

កា : មានន័យថាអ៊ំខ្លាំង? (សើច)

ភីន ៖ អ៊ំនៅជាមួយម៉ែសម្តេច ហ៊ុន សែន អត់មានអ្នកណាតក់ស្លុតទេ អត់មានអ្នកណាធ្វើបាន ដូចគាត់ទេ ខ្ញុំប្រាប់ ។

កា ៖ ចឹងសុំសួរអ៊ំម៉ង ។

ភីន ៖ បាទ!

កា ៖ ចឹងអ៊ំមានឈ្មោះអី?

ភីន ៖ សំ ភីន ។

កា ៖ អ៊ំកើតឆ្នាំណាដែរ?

ភីន ៖ ហ៊ើ! អ៊ីឆ្នាំប៉ុន្មាន ៥៤ ។

កា ៖ ១៩៥៤?

ភីន ៖ អញមិនប្រាប់ត្រង់ទេ ខ្លាចគេធ្វើអំពើ ។

កា ៖ អ!លោកអើយ ខ្ញុំមិនដឹងផ្ទះគ្រូធ្វើអំពើនៅណាទៀត ហើយមិនដឹងធ្វើអំពើអ៊ំដើម្បីអី ទៀត ។ (សើច) ទីកន្លែងកំណើតនៅណាវិញ?

ភីន ៖ ហ៊ើ! នៅណាស្រុកយើងខេត្តតាកែវ ។

កា ៖ ខេត្តតាកែវ កើតនៅភូមិណា ឃុំណា ស្រុកណា?

ភីន ៖ ហ៊ើ!អ៊ី អញមកយូរហើយ ភ្លេចភូមិទៀត ។

កា ៖ ស្រុកព្រៃកប្បាស ស្រុកអីណា ខ្ញុំស្គាល់ព្រៃកប្បាសមួយ ។

ភីន ៖ នាងឯងនៅនឹង?

កា ៖ អត់ទេ ខ្ញុំមានពួកម៉ាកនៅនឹង ហើយធ្លាប់ទៅលេង ។

ភីន ៖ ហើយស្រុកមែនទែននៅភ្នំពេញ ។

កា ៖ ភ្នំពេញម៉ង?

ភីន ៖ នៅម្តុំណា ភ្នំពេញ?

កា ៖ នៅទួលសង្កែ ។

ភីន ៖ ទួលសង្កែ សុទ្ធតែបឹងនឹង មានមនុស្សដែរ?

កា ៖ ហ៊ើ! អ៊ំមើលមួយសារទៀតមើល(សើច) ចាក់ដីឡើងកប់បឹងអស់ហើយ ។

ភីន ៖ កប់ហើយ ទួលសង្កែមានទួលមួយ រកកណ្តុរនៅមិនបានផង ។

កា ៖ អត់ទេ ឥឡូវអ៊ំឯងទៅមើលសុទ្ធតែវីឡា ផ្ទះខ្ញុំមិនបានប៉ុនផ្ទះអ៊ំផង ។

ភីន ៖ ហ៊ើ! អត់ទេ នៅទួលនឹងសុទ្ធតែខ្លាំងហើយបាននៅបាន ។

កា ៖ អត់ទេ នៅទួលគោកបានខ្លាំង នៅទួលគោកបានផ្ទះអ្នកមាន ម្តុំទួលសង្កែផ្ទះអ្នកអន់ៗ ។

ភីន ៖ កាលនឹងអឹំនៅជិតទួលសង្កែនឹងឯង នៅខាងនេះព្រែកញ្ញោនៅជាប់នឹងផវ ។

កា ៖ ចុះអត់ចាំស្រុកកំណើតទេ?

ភ់ន ៖ ហ៎! អញចាំ ស្រុកអញដែលលាក់ធ្មើស្អី ។

កា ៖ ស្រុកអីអ៉ឹ?

ភីន ៖ នៅ សួរមើលឲ្យត្រូវសំនួរគេ កុំឲ្យខុស ។

កា ៖ អ៉ឹៗកើតនៅភូមិណាដែរ?

ភីន ៖ កើត បើនិយាយរឿងកើត អញអត់ដឹងទេ ខ្ញុំអត់ដឹងទេ ម៉ែប្រាប់ថាកើតនឹងព្រៃ កើតជំនាន់ឥស្សរៈ កើតរត់គេច្បាំងគ្នាដែរតើ កើតព្រៃ មិនបានកើតស្រុកទេ ដល់ទីចុងបំផុតអ៉ឹមកនៅព្រៃដែរ ។

កា ៖ នៅស្រុកណា? ព្រៃនឹងក៏មានឈ្មោះភូមិឃុំដែរ?

ភីន ៖ អូ! ភូមិអ៉ឹប្រាប់ ភូមិត្រឡាច ។ ប៉ុនកើតៗព្រៃ ។

កា ៖ ឃុំ?

ភីន ៖ ឃុំក៏អានឹង ។

កា ៖ ស្រុក? អត់មានស្រុកត្រឡាចទៀតទេ ខ្ញុំអត់ដែលឮស្រុកត្រឡាច(សើច) ។

ភីន ៖ ហ៎! មានតើ ស្រុកកំពង់ត្រឡាច កំពង់ឆ្នាំងមាន ។

កា ៖ ហ្នឹងហើយមានតែកំពង់ត្រឡាច បើត្រឡាចអត់មាន(សើច) ។ ស្រុកអីគេអ៉ឹ?

ភីន ៖ ស្រុកទ្រាំងកាលនឹង ។

កា ៖ ទ្រាំង ខេត្តតាកែវ?

ភីន ៖ អឺ!

កា ៖ អានេះនៅភូមិជើងភ្នំ ឃុំត្រពាំងប្រិយ៍ ស្រុកអន្លង់វែង ធំណាស់អន្លង់វែង ។

ភីន ៖ ហ៎! មិនធំទេ តូចជាងភ្នំពេញ ។

កា ៖ ហ៎! ស្រុកមួយទាំងមូល ភ្នំពេញមានរាជធានីមួយ គួរតែធំ ។ ឧត្តរមានជ័យ ។

ភីន ៖ អក្សរស្អាត ចឹងបានគេឲ្យរៀន?

កា ៖ អូ! អ៉ឹអក្សរគេគ្រិចសោះ ថាស្អាត ។ ចឹងអ៉ឹដែលចេះតែគិត ឬនឹកឃើញជារឿយៗនៅព្រឹត្តិការណ៍ដែលបានកើតឡើងនៅក្នុងសម័យ៣ឆ្នាំនឹងទេ?

ភីន ៖ យី! សង្គ្រាមណា៣ឆ្នាំ?

កា ៖ ៣ឆ្នាំ សម័យ៣ឆ្នាំ ៨ខែ ២០ថ្ងៃ ។

ភីន ៖ អូ! សម័យនង់ អញពិបាកចង់ងាប់ គិតអីទៅ ។

កា ៖ ចឹងអ៊ំចេះតែនឹកឃើញដល់សម័យនឹងអត់ ដល់ឥឡូវនឹង?

ភីន ៖ នឹកឃើញរឿងពិបាកដែរតើ ប៉ុនពិបាកមួយជីវិតហើយអ៊ំ ។

កា ៖ នឹកឃើញតិចតួច ឬក៏នឹកឃើញខ្លាំងដែរ?

ភីន ៖ ហ៊ើ! នឹកឃើញខ្លាំងក៏មិនដឹងទៅរកពីណាមក នឹកឃើញល្ហម រវល់នឹកឃើញគេខ្លាំងពេក មិនស្រាប់ខ្លួនឯង ។

កា ៖ ចុះដែលយល់សប្តិអាក្រក់អត់អ៊ំ?

ភីន ៖ ហ៊ើ! យល់សប្តិស្អីអី ដេកយល់សប្តិឃើញថាអត់បាយ ខំប្រឹងរកបាយហូបឲ្យតែគ្រប់ទៅ ។

កា ៖ ចឹងយល់សប្តិដែរ? ចុះឥឡូវអ៊ំមានអារម្មណ៍មិនចង់រវីរវល់ ឬក៏ទាក់ទងជាមួយអ្នកដទៃអត់ ដូចថាចង់នៅម្នាក់ឯងអីអត់?

ភីន ៖ ចុយ! ឥឡូវគេនៅជាមួយកូន ជាមួយចៅគេ ។

កា ៖ ខ្ញុំចាញ់អ៊ំម៉ង(សើច) ។

ភីន ៖ ថាមិនចង់រវីរវល់នៅជាមួយពីណា កូនចៅអ្នកជិតខាង ។

កា ៖ ទេ! ចុះមានអារម្មណ៍ភ្ញាក់ផ្អើល ឆាប់ភ័យ ឆាប់ខ្លាចអីទេ?

ភីន ៖ ហ៊ើ! អ៊ំអត់ចេះភ្ញាក់ទេ គ្រាប់ផ្លោង អត់ភ្ញាក់ផង ។

កា ៖ ចុះគេបាញ់នៅថៃ?

ភីន ៖ អឺ! អត់មានភ្ញាក់ទេ ភូមិនេះ អត់មានទៅណារលីង ។

កា ៖ អត់មានប្រុងខ្លួនអី?

ភីន ៖ អឺ! អាក្រៅពីនឹងរត់បាត់អស់ហើយ ។

កា ៖ ចុះយប់ឡើងអត់មានពិបាកសម្រាន្តអីទេ?

ភីន ៖ ហ៊ើ! យប់ឡើងថ្ងៃណាស្រួលខ្លួន សម្រាន្តស្រួល ថ្ងៃណាមិនស្រួលអត់ដែរ ចាស់ហើយ ។

កា ៖ ចុះពេលធ្វើការអីចឹង យើងពិបាកផ្តង់អារម្មណ៍ធ្វើការអីមួយទេអ៊ំ?

ភីន ៖ ហ៊ើ! ចាស់ៗហើយពិបាកណាស់ ។

កា ៖ ពិបាកដែរ?

ភីន ៖ អឺ!

កា ៖ ចឹងអត់មានឆាប់ឆេវឆាវអីទេ?

ភីន ៖ ហ៊ើ! តែថ្ងៃណាមួរម៉ៅ ព្រោះអ៊ំត្រូវគ្រាប់ដែរនឹង ។

កា ៖ អ! ចឹងឆេវឆាវដែរ?

ភីន ៖ អឺ!

កា : ត្រូវកន្លែងណា?

ភីន : ត្រូវពិការជើងហើយ ។ ហើយនាងឯងមិនទាន់កើតទេ អ៊ំត្រូវនោះ សួរអ៊ំពិបាកប្រាប់ដែរណា៎ ។

កា : ខ្ញុំកើត៨៩?

ភីន : អឺ! ឯងកើត៨៩ អញពិការតាំងពី៧៤នោះ ។

កា : អូ! ប្រឡំប្រាប់អ៊ំបាត់ ធ្វើអំពើចូល(សើច) ។

ភីន : ខ្លាចធ្វើអំពើទៀត ។

កា : ចុះអ៊ំនិយាយចឹង ខ្ញុំនិយាយវិញទៅ?

ភីន : អ៊ំអត់បេះទេធ្វើអំពើ ។

កា : រាល់ថ្ងៃនឹង អ៊ំដែលចៀសវាសនៅសកម្មភាពទាំងឡាយណាដែលបណ្ដាលឲ្យអ៊ំនឹកឃើញរឿងក្នុងសម័យពតឆ្នាំ?

ភីន : លែងនឹកហើយ យូរហើយ អត់រវល់នឹកអីទៀតទេ ព្រោះពិបាកវាហួសហើយ បើនឹកទៀតឆាប់ងាប់ មនុស្សនឹកច្រើនគិតច្រើនឆាប់ងាប់ ។

កា : ចឹងអ៊ំនៅចងចាំនូវព្រឹត្តិការណ៍នឹង? ចងចាំដែរ?

ភីន : ចាំតើ ប៉ុនយើងទៅនឹកអីពេក បើវាហួសបាត់អស់ទៅហើយ ។

កា : ចុះពេលអ៊ំចេញមកពី សម់យនឹង អ៊ំមានអស់សង្ឃឹមទៅថ្ងៃមុខ?

ភីន : សម័យណា?

កា : ចេញពីសម័យពតឆ្នាំ?

ភីន : មិនអស់សង្ឃឹម បើយួនដេញ អត់រត់វីសងាប់ ។ ដឹងយួនចូលដែរ នាងឯង?

កា : ដឹង អានសៀវភៅដឹង ។

ភីន : អឺ! យួនឈ្លានពានស្រុកខ្មែរ ហ៎! គេអត់ឲ្យរៀនដឹង ។ គេឲ្យរៀន ។

កា : គេមិនថាយួនឈ្លានពានទេ គេថាយួនមកជួយរំដោះ ។

ភីន : អឺ! ថាយួនជួយរំដោះ អឺ!ល្អៗត្រង់ខុស ។

កា : ប៉ុន្ដែការពិតម៉េចទៅ?

ភីន : ល្អត្រង់ខុស ។

កា : ការពិតម៉េចទៅអ៊ំ?

ភីន : ខ្លាចងាប់នៅទួលស្លែង នៅអីណាទាំងអស់គឺ រួមនឹងហើយ ។ ហើយរឿងអីគេកាត់ទោសតា ចាស់ៗនឹង រឿងផលប្រយោជន៍របស់គេទេនាងអើយ អ៊ំប្រាប់ប៉ុននឹងឯង ។ ក្មួយឯង

សួរ អនិយាយចឹងឯងតាមសំនួរគេ ប៉ុនឲ្យរឿងពិតគេអត់ចារឲ្យនាងឯងរៀនទេ។ គេអត ឲ្យ រៀនទេ គេឲ្យរៀនតែកន្លែងណាដែលអាក្រក់តែប៉ុននឹងទេ។ សម័យបេ៥២ នាងឯង កើតមិនទាន់ទេ បើឪពុកអាចទាន់។

កា : ចាំ! ឪពុកខ្ញុំ៤០ជាង។

ភីន : ៤០ប៉ុន្មាន៤០ជាងត្រូវហើយ កើតទាន់ហើយ។

កា : គាត់ថានៅកុមារ នៅតូច។

ភីន : អ!កុមារវែកដីដំបូក អឺដីងទាំងអស់ អឺនៅធ្វើទាហានកាលនោះ២០០យប់ ២០០ថ្ងៃជាង បេ៥២ទម្លាក់ស្រុកខ្មែរ អត់មានភ្លើងស្ងាត់ទេ ភ្លើងក្រហមទាលនាងឯងមើលទៅនេះក៏ក្រហមៗ ២៤ពេញ២៤ម៉ោង។

កា : ខាងណាអ្នកទម្លាក់?

ភីន : អានឹងខាងអាឲ្យលុយនាងឯងរាល់ថ្ងៃនឹង អ្នកទម្លាក់។

កា : អាមេរិចកាំង?

ភីន : អឺ! អាមេរិចកាំង អឺប្រាប់ៗ តែបើមកសម្លាប់ខ្មែរច្រើន អាមេរិចនឹងទម្លាក់គ្រាប់បែកស្លាប់មួយចំនួនហើយ ផុតៗពូជមួយភូមិនាងឯង ទម្លាក់ស្រុកខ្មែរ២០០យប់ ២០០ថ្ងៃជាង។ ទម្លាក់អត់ឈ្នះខ្មែរ បោះឆ្នោតដកទ័ព ដកយន្តហោះបេ៥២។ ហើយយន្តហោះងងឹតមេឃមើលថ្ងៃមិនឃើញទេ។ នាងឯងមិនដែលឃើញទេ យន្តហោះសម័យឥឡូវគេអត់ទាន់ហោះឲ្យឃើញទេ បើសម័យនោះមានហើយងងឹតមេឃ មើលថ្ងៃអត់ឃើញទេ។ គេមកសម្លាប់ខ្មែរយើង តែងាប់មិនអស់ទេ នៅសល់ៗ នៅពួកងាប់ៗនឹងហើយ គេគាស់ឆ្អឹងក្បាល អាពួកងាប់នឹង។ នាងឯងដែលទៅឃើញស្រុកនេះមួយទេ?

កា : ស្រុកណាអឺ?

ភីន : ស្រុកត្រាំកក់ ខេត្តតាកែវ នៅអង្គរការ គេហៅភូមិអង្គរការ គ្រាន់ខ្មោចងាប់ដោយសារយន្តហោះ៦០០០នាក់ នៅស្តុប៣០០០នាក់ អាខ្មោចងាប់យន្តហោះទម្លាក់ៗ ប៉ុនគេគាស់យកទៅបាត់អស់ហើយ។

កា : ឥឡូវនៅមានស្លាក់ស្នាមឲ្យយើងទៅមើលដឹង?

ភីន : ស្លាក់ស្នាមអី គេធ្វើភូមិអស់ហើយ។ តែក្នុងវត្តគេអត់ធ្វើទេ វត្តនៅវត្តដដែល តែអង្គរកានឹងអត់មានវត្តទេ គេធ្វើកន្លែងឃោសនាការ អាកន្លែងកប់សពវិមាន គេហៅវិមានកាលនឹង។ តែគេគាស់យកទៅដាក់គរនៅទួលស្លែង។

កា : អូ! យកពីនឹងទៅដាក់នៅទួលស្លែង គេចោទថា?

ភីន : គេចោទថា អ្នកនឹងសម្លាប់ តែតាមពិតគុកទួលស្លែងវាមានស្លាប់មែន មនុស្សៗជាប់គុកសម័យឥឡូវក៏ងាប់ អាណាមិនធ្វើតាមគេងាប់ចឹងឯង។ សម័យនោះវាពិបាកណាស់ គ្មានអ្នកណាជួយដូចឥឡូវ។ ឥឡូវគេជួយលុយទាំងហោប៉ៅ អង្ករទាំងហោប៉ៅៗនៅមនុស្សងាប់មនុស្សដើរសុំទានគេ។ ហើយសម័យសង្គ្រាមនោះ យើងវៃឈ្នះអាមេរិចផង មានអាមេរិចណាមួយជួយមួយគ្រាប់។ ពេលនេះអាមេរិចវាខឹង យើងនេះឯង វាសុខចិត្តយកលុយមកជះឲ្យពេញស្រុកខ្មែរទៅ ថាអាមនុស្សខ្មែរក្រហមសម្រាប់ឈ្នះវានឹង កាត់ទោសឲ្យអស់ ងាប់ចោលអស់ទៅ ទុកធ្វើអីអាមនុស្សវៃឈ្នះគេ។ អាមេរិចនឹង តាំងពីកើតមកដែលឃើញវៃចាញ់ណាលើសកមលលោក អត់មានទេ។ មើលក្នុងទូរទស្សន៍ឃើញទេ អត់មានចាញ់ទេ ម៉េចទៅចាញ់អាកូនខ្មែរក្រហមនុស្ស៨លាននាក់កាលនឹង មិន១៨លានដូចឥឡូវទេ។ អាមេរិចរត់ ចាញ់ម៉ង ចាញ់ទាំងខ្មែរចាញ់ទាំងនៅយួនទៀត នៅ២នាក់។ ខ្មែរយើងឈ្នះអាមេរិចមុនយួន ខ្មែរយើងឈ្នះ១៧ យួនឈ្នះថ្ងៃ៣០ ខុសត្រូវគ្នាប៉ុន្មានថ្ងៃ។

កា : អ! ១៧មេសា?

ភីន : អឺ! ១៧មេសា អានឹងខ្មែរឈ្នះអាមេរិច ហើយដែលយួនឈ្នះអាមេរិចដែរ យួនឈ្នះថ្ងៃ ៣០ ក្រោយយើង១០ប៉ុន្មានថ្ងៃ ១៧ ហើយ៣០។

កា : ១៣ថ្ងៃ?

ភីន : អឺ! ១៣ថ្ងៃ ហើយក្នុងប្រវត្តិសាស្ត្រ យួនគេដាក់ថាគេឈ្នះអាមេរិចមុនខ្មែរ។ ប៉ុនអ៊ំមិននិយាយទេអានឹង និយាយរឿងគេមកធ្វើបាបខ្មែរ។ ពូជពង្ស វង្សត្រកូលអ៊ំអស់ប៉ុន្មានគ្រួសារដុតៗងាប់។

កា : ម៉េចចឹង?

ភីន : ចុះយន្តហោះទម្លាក់ត្រូវមួយគ្រាប់ៗដែលនៅ គ្រាប់បេ៥២មួយគ្រាប់ៗប្រវែង៧ម៉ែត្រ។

កា : កាលនឹងទម្លាក់ខេតច្រើន?

ភីន : នេះរណ្តៅមិនទាន់អស់ទេ នាងឯងដើរមើល បើគេបង្ហាញអត់ទាន់អស់ទេរណ្តៅ មួយគ្រាប់ ១២ម៉ែរត៤ជ្រុង ចេញទឹកខៀវ មិនបាច់ជីកទេ។ គ្មានព្រះអង្គណាទៅពួនបានទេ តែត្រូវហើយងាប់ គ្មានបានយកសពខ្មោចមកកប់អីទៀតទេ ចប់ វាកប់ខ្លួនវា បើនិយាយខ្មែរយើងវាពិបាកណាស់កាលនោះ យំមិនចេញទឹកភ្នែកទេ។ ម៉ែឪប្អូនឯងសរសើរថារស់បានឃើញមុខគេសព្វថ្ងៃនេះ ដូចអ៊ំចឹង គេរស់ភាគតិចណាស់ ដូចគេចោទថាខ្មែរក្រហមសម្លាប់ដុតពូជមែន ជឿចឹងមែន ប៉ុនគ្រាន់និយាយផ្ទុយតិចពាក្យ។ វាដុតពូជដូចគ្នាមែន ប៉ុនែអាមួយដុតពូជដោយខ្មែរសម្លាប់ខ្មែរ អាមួយដុតពូជដោយពួកក្រៅមកសម្លាប់ខ្មែរ។

កា ៈ ចុះអ៊ំគិតថា យួនអ្នកមកសម្លាប់?

ភីន ៈ យួនក៏សម្លាប់ អាមេរិចក៏សម្លាប់ខ្មែរ ។

កា ៈ តែខ្មែរក្រហម អត់បានសម្លាប់ប្រជាជនទេ?

ភីន ៈ ខ្មែរក្រហមក៏មានគ្រោះថ្នាក់ក្នុងសម័យនឹង គ្រោះថ្នាក់ដូចនៅក្នុងគុកក្នុងអីនឹង ដែលគេចាប់ដាក់គុកចំណោមមនុស្សដែលនិយាយមនស្តាប់គ្នា ។ ឥឡូវនាងឯងប្រៀបធៀបដូចឥឡូវរដ្ឋាភិបាលមនឲ្យយើងជក់ថ្នាំញៀន មិនឲ្យយើងលួចប្លន់គេ ។ ហើយយើងទៅលួច-ប្លន់ខុសច្បាប់ចឹង គេចាប់ចឹងដូចគ្នា គេមានច្បាប់ដូចគ្នា មិនអត់ទេ ។

កា ៈ ចឹងបានន័យថាអ្នកជាប់គុកអីនៅទួលស្លែងនឹង ដោយសារគាត់នឹងធ្វើខុសនឹងច្បាប់?

ភីន ៈ អឺ! បើមិនខុស អ្នកណាគេចាប់ចុះ ម៉ែឪនាងឯងខុសដែរចុះ គេចាប់ដែរ អត់ចាបទេ ។ យើងដឹងថាធ្វើដឹងថានេះហើយ កុំប្រឆាំងសង្គមគេមួយៗដែលយើងប្រឆាំងគេទៅហើយ ឥឡូវមិនជឿ នាងឯងនៅរៀនខ្ពស់ក៏ដោយ ទៅប្រឆាំងនឹងគេ ។ ទៅហើយៗអត់មាននៅទេ ទោះបីមិនស្លាប់ក៏វេទនាក្នុងគុកហើយ ។ ដូចតា ជុំ មុី ដែលធ្វើសាក្សីរាល់ថ្ងៃ ដោយសារគាត់ធ្វើល្អនៅក្នុងគុកហើយ ដែលគាត់រស់ហើយ ។ បើគាត់ធ្វើមិនល្អក្នុងគុកទៅទៀតហើយ ។

កា ៈ តា វណ្ណាត ស្លាប់បាត់ហើយ?

ភីន ៈ អឺ! ស្លាប់បាត់ហើយ ហ្នឹងហើយ គាត់អាយុ៦០ជាង?

កា ៈ ចា៎! ៦៦ ។

ភីន ៈ គាត់មិនទាន់ដល់ស្លាប់ ប៉ុនរោគាគាត់ ។

កា ៈ អត់ទេ ស្លាប់បាត់ហើយ ។

ភីន ៈ អើ! ហ្នឹងហើយ អាយុរបស់គាត់មិនទាន់ដល់ស្លាប់ទេ ប៉ុន្តែរោគរបស់គាត់ទាញឲ្យទៅហើយ

កា ៈ ចឹងរាល់ថ្ងៃនឹង អ៊ំតែងតែចៀសវាងគិតពីរឿងសម័យនឹង ព្រោះអីសុខសប្បាយ?

ភីន ៈ អ៊ំលែងចង់គិតហើយ គិតអីពិបាកណាស់ គិតទៅទៀតមិនកើតទេ រស់នៅសម័យគេសប្បាយ យើងនៅគិតទៀត ឆាប់ហើយ ឆាប់មិនបានឃើញមុខចៅឯង ។

កា ៈ ចឹងមានអារម្មណ៍មិនទុកចិត្តអ្នកដទៃ?

ភ៊ន ៈ មិនទេ មិនទុកចិត្តអ្នកណាទេ លែងហើយ ។

កា ៈ ម៉េចចឹងអ៊ំ?

ភីន ៈ មិនទុកចិត្តគេក៏អត់បានការអីដល់យើងដែរ ខ្ញុំគិតចឹងហើយឥឡូវនឹង គ្មានប្រយោជន៍អីនឹងទុកចិត្តគេ គេអត់មានចិញ្ចឹមយើងទេ មានតែយើងរកស៊ីចិញ្ចឹមខ្លួនយើង ខំរកស៊ីទៅ រស់

បានប៉ុន្មានរស់ប៉ុននឹង ។ ហើយចិញ្ចឹមកូនចិញ្ចឹមចៅយើងកុំឲ្យវាពិបាកទៅបានហើយ ព្រោះយើងរស់ហើយ យើងលែងខ្លាចហើយ ។ ខ្លាចៗ ដោយជម្ងឺដង្កាត់អី ។

កា : ចុះពិបាកការបំពេញការងារផ្សេងៗ ប្រចាំថ្ងៃ?

ភីន : ហ៎ោ! ពិបាកហើយ អ៊ំពិការ ពិបាក ។

កា : អ៊ំឥឡូវធ្វើអីខ្លះដែរ?

ភីន : ធ្វើអីទេ ។

កា : ចំការ?

ភីន : អឺ! ចំការ ហើយស្រែ ។

កា : ចំការអីគេ?

ភីន : ចំការតិចតួចនាង ដាំចេក ដាំអីចំការមិនធំទេ ដីមួយហត្ថ ។

កា : មិនធំទេ តែអ្នកនៅនេះដីសុទ្ធតែហិតា(សើច) ។

ភីន : អឺ! ដីហិតា តែដីវាមិនថ្លៃ ដូចភ្នំពេញ ថ្លៃណាស់ភ្នំពេញ ។

កា : ចំការអីអ៊ំមានដាំពោត?

ភីន : ពោតអត់ ដាំឆ្នាំនេះ ឆ្នាំទៅដាំអត់បានហូប ខឹងពេករវល់សត្វស៊ី ឆ្នាំនេះឈប់ដាំ ។

កា : ដំឡូង?

ភីន : អត់ទេ ។

កា : ពូគេល្បីដាំដំឡូងច្រើននៅនេះ?

ភីន : ដាំច្រើន ប៉ុនមិនទាន់ដឹងមានតម្លៃយ៉ាងណាទេ អត់ទាន់ដឹង ។

កា : តែខ្ញុំសង្ស័យថា ដាំច្រើនធ្លាក់ថ្លៃ?

ភីន : វាចឹងហើយ ដែលពូថៃៗចឹងឯង តែក្រសួងកសិកម្មប្រកាសដាំដំឡូង ហើយច្បាស់ជាថោកហើយដំឡូងទៅថ្ងៃក្រោយ បើប្រកាសដាំក្រចៅ ដាំដំឡូងត្រូវហើយ ។ ចឹងហើយស្រុកពាណិជ្ជកម្មជួយចឹង ។ ឥឡូវស្រុកខ្មែរយើងរបៀបនេះដែរ ព្រោះយើងដាំច្រើនថៅកែវា បន្ទោកព្រោះទំនិញទីផ្សារសកលលោកវាអត់ថោក ប៉ុនខ្មែរយើងវាបន្ទោកគ្នាឯងចឹងទៅ គេអ្នកដើរទិញគេបន្ទោកយើងទៅ ។

កា : ចា៎! គេយកលក់ថ្លៃ?

ភីន : អឺ! គេយកលក់ថ្លៃ បើចឹងគេមិនមែនធ្វើនាយទុន ។ នាងឯងខំរៀនឲ្យបានធ្វើនាយទុនគេទៅ ។ ស្គាល់ទេនាយទុន?

កា : អត់ស្គាល់ផង ។

ភីន : នាយទុនពួកគេអ្នកមានធំៗ ។

កា : មានធ្វើការអីក្រៅពីបម្រើរដ្ឋ ។

ភីន : អឺ! ធ្វើការបម្រើរដ្ឋបានប្រាក់រីគ្រែត បើក្រៅពីនឹងអត់បានទេ មានតែធ្វើទាហាន ធ្វើមន្ត្រីរាជការបានរីគ្រែត យើងចាស់ៗទៅ បានប្រាក់រីគ្រែតហូបទៅ ។

កា : ចុះអ៊ំមានអារម្មណ៍ថាបន្ទោសខ្លួនឯង នៅពេលដែលអ៊ំរស់រានមានជីវិតពីពេលនោះមក?

ភីន : ខ្លាចយើងបន្ទោសខ្លួនឯង?

កា : ចា៎!

ភីន : អត់មានបន្ទោសទេកាលនោះ បន្ទោសធ្វើអី កុំបន្ទោសគេ បន្ទោសយើងវិញឆ្កួតខ្លួនឯងអាមួយគេឡើងមក គេអំពាវនាវឲ្យយើង អាពីរឡើងមកគេអំពាវនាវឲ្យយើង ដូច្នេះយើងអ្នកតូចតាច ចាំតែធ្វើតាមគេទេ នាំងឯងជឿទៅ ។ ដូចនាំងឯងឥឡូវចឹង គេអំពាវនាវថាហ៎! នាំងរៀន ដើម្បីធ្វើការយកលុយចាយ ទៅនឹងគេហើយរៀនអត់ឈប់ទេ មិនចង់យកប្តីយកអីទៀត ខំរៀនឲ្យបានថ្នាក់ខ្ពស់ចឹងឯង ។ កាលមុនចឹងដែរ គេថាជ័យយោ!សម្តេចឪ អ្នកណាមិនទៅដុតផ្ទះចោល ពាក្យហ្នឹងមាននិយាយ ។

កា : ចឹងកាលហ្នឹងអ៊ំចូលបដិវត្តន៍ឆ្នាំណាទៅ?

ភីន : ហឺ! តាំងពីឆ្នាំ៧១នោះ ។

កា : អាយុប៉ុន្មាន អ៊ំកាលនោះ?

ភីន : កាលចូលនោះអាយុ១៨ ១៥ដឹង អញក្មេងហើយកាលនោះ ៧១ ឯងគិតមើល ។

កា : អ៊ំចូលដោយសារម៉េចៗបានគិតថាចូល?

ភីន : អើ! ដោយសារគេធ្វើសង្គ្រាមស្រុកយើងនឹង ថាជ័យយោ!សម្តេចឪ អ្នកណាមិនទៅដុតផ្ទះចោលនឹង ។

កា : មួយទៀតគេមកពីរបបលន់ នល់?

ភីន : ហ៎! អាមេរិចកាំងចង់ធ្វើរដ្ឋប្រហារឲ្យលន់ នល់ កាន់អំណាច វាទម្លាក់សម្តេចសីហនុរាល់ថ្ងៃនេះ ដឹងទេ សម្តេចតាគេហៅសម្តេចតាៗ ទម្លាក់តានឹង ។

កា : បន្ទាប់មកសម្តេចឪក៏ប្រកាសឲ្យចូលព្រៃម៉ាគី?

ភីន : អឺ! ហើយឯងនេះចូលឡើងរតឹស ឆាប់អស់កូនចៅ ។

កា : ព្រៃម៉ាគីព្រៃនៅណា?

ភីន : ចូលកាន់កាំភ្លើង គ្មានព្រៃណាឲ្យនាំងឯងចូលរួមក្នុង ។

កា : ខ្ញុំចេះឆ្ងល់ព្រៃម៉ាគីនៅណាស្រុកខ្មែរ?

ភីន :	គ្មានទេ គេឲ្យយើងចូលតស៊ូ ។

កា :	ម៉ាគី ភាសាអីគេទៅ?

ភីន :	អឺ! ម៉ាគីៗភ្លើងហើយ សាមគ្គីគ្នាកាន់ភ្លើងដុតអាមួយម្ខាងៗនិយាយឲ្យខ្លី ។ ទៅលប់បើកវចនានុក្រមមើល គេនិយាយម៉េច ។

កា :	ខ្ញុំចេះឆ្ងល់រកព្រៃម៉ាគីនៅណាស្រុកខ្មែរ ខ្ញុំអត់ដែលឃើញស្គាល់ព្រៃ ។

ភីន :	អត់ទេ ។ កាលនឹងសម្តេចគាត់នៅស្រុកចិន គាត់អត់ចេញទេពីស្រុកចិន ព្រោះចិនជួយគាត់ជួយផ្ទះសម្បែងកន្លែងនៅ ប៉ុនស្រុកខ្មែរយើងចិនគេមិនដែលមកវៃជំនួសទេ អត់ទេ ។ មានតែអាមេរិច ហើយនឹងយួនទេដែលគេមកផ្ទាល់ៗ ហើយពួកគេចោទថាចិនមកវៃ អត់មាន ។

កា :	គេថាខ្មែរក្រហមនឹងមានចិននៅពីក្រោយ?

ភីន :	មានចិននៅពីក្រោយ ចិននៅផ្ទះគេមែន គេមានមកនេះណា ។

កា :	តែអានឹងមិនពិតទេ?

ភីន :	អឺ! គេនៅពីក្រោយមែនវាពិតតែនៅពីក្រោយហើយ តែគេអត់មានមនុស្សអីមកជាមួយខ្មែរក្រហមម្នាក់ទេ គ្មានទេ មានតែពួកអាមេរិចហើយពួកគេនេះទេ ដែលគេមកផ្ទាល់ៗ ។

កា :	ចឹងកាលពីមុនរបបកម្ពុជា ប្រជាធិបតេយ្យនឹង អ៊ំមានសមាជិកគ្រួសារប៉ុន្មាននាក់?

ភីន :	ហ៊ើ! ៥ ។

កា :	៥នាក់ទាំងឪពុកម្តាយ៧នាក់?

ភីន :	៧ ។

កា :	ហើយដល់ពេលចេញមកមានបាត់បង់បងប្អូនអីទេ?

ភីន :	ហឺ! ម៉េចមិនបាត់ បើនៅខ្ញុំមួយទេ ប៉ុន្មាននាក់នៅស្រុកនឹង ។ បាត់បង់ដែលបងប្អូន ជីដូនមួយជីទួតមួយ ពោះមួយបង្កើតនៅទេ ខ្ញុំអត់មានបាត់បង់ទេ ព្រោះអាពោះមួយបង្កើតរបស់ខ្ញុំវាអត់ចេះប្រឆាំងគេទេ ។ នៅរបបខ្មែរក្រហមក៏ធ្វើតាមគេ របបលន់ នល់ក៏ធ្វើតាមគេ មករបបហ្ស៊ីងក៏ធ្វើតាមគេ មិនងាយងាប់ទេមនុស្សចឹង ។

កា :	ឲ្យធ្វើតាមគេមនងាយទេ?

ភីន :	ឲ្យធ្វើតាមគេមិនងាយងាប់ទេជឿខ្ញុំ បើថាគេមិនឲ្យទៅលួចគោ ឯងទៅលួចគោស្លាប់ហើយ អត់លួចរស់ទេ គេមិនឲ្យទៅលួចស្លឹកគ្រៃ ទៅលួចស្លឹកគ្រៃងាប់ហើយ ។

កា :	ចឹងកាលនឹងឪពុកម្តាយរបស់អ៊ំប្រកបការងារអីដែរ?

ភីន :	ហឺ! ធ្វើស្រែ ។

កា ៖ កសិករ?

ភីន ៖ អឺ! ធ្វើស្រែ ។

កា ៖ កសិករ កាន់ព្រះពុទ្ធសាសនាជម្មតា?

ភីន ៖ អឺ! អត់មានអ៊ីស្លាមមួយបាតអីទេ ។ តែសាសនាក៏ជឿដែរ អត់ខ្លាំងទេ ។

កា ៖ ចឹងកាលនោះក្រុមគ្រួសារអ៊ំមានជីវភាពយ៉ាងម៉េចដែរ?

ភីន ៖ ហឺ! ធ្វើស្រែមិនសូវធូរទេ ។

កា ៖ មធ្យម ឬក៏ក្រ គិតទៅមធ្យម?

ភីន ៖ ទេ! យើងមិនក្រពេកទេ យើងមានដីធ្វើអីដែរ ។

កា ៖ មធ្យម?

ភីន ៖ អឺ!

កា ៖ ហើយមិនទាន់រៀបការទេ មុនៗ?

ភីន ៖ យ៉េ! អត់ទេវើយ ធ្វើទាហានឡើងប៉ុន្មានឆ្នាំ មិនបានការទេ ។

កា ៖ ការឆ្នាំណាវិញ?

ភីន ៖ ការអត្តាល់យួនចូល យួនវ៉ៃស្រុកខ្មែរ៧៩ ។

កា ៖ ការច្រើនគូ ឬមួយគូ?

ភីន ៖ ហ៊េ! កាលការ ៦គូទេ មិនតិច អត់ច្រើនទេ ។ ទឹកដោះគោមួយឡាំង មាន៦ស៊ីអត់អស់ហូបអត់អស់ ។

កា ៖ ចឹងដល់ពេលការនឹងយើងស្ម័គ្រចិត្តខ្លួនឯងស្រឡាញ់គ្នាដែរតើ?

ភីន ៖ អឺ! ហ្នឹងហើយ ។

កា ៖ អត់មានអ្នកណាគេបង្ខំ?

ភីន ៖ អ្នកណាគេទៅ ។ ប៉ុនសម័យនោះអ៊ំនិយាយប្រាប់តិច អត់មានមនុស្សមេម៉ាយដូចឥឡូវទេ ។ ម៉េចចឹងមេម៉ាយអាត្រូវគ្រាប់ភ្លាម ងាប់ម៉េម៉ាយភ្លាម ។ ប៉ុនតិចទៀត គេរកប្តីឲ្យអត់ឲ្យមេម៉ាយទេ ។ មើលឥឡូវអ៊ំចង់និយាយប្រាប់តិច អារឿងមនុស្សពីមុនដែលគេថា ទាញគេឲ្យមានប្តីមានប្រពន្ធ ហើយចេះតែចោទថាគេបង្ខំចិត្ត បង្ខំកាយណា វាមិនមែនទេ ។ គេមាននយោបាយមួយចេះ គេមិនឲ្យមនុស្សនៅមេម៉ាយ អត់មានប្តីមានប្រពន្ធទេ ប៉ុល ពត ធ្វើចឹងឯង ។

កា ៖ ម៉េចចឹង?

ភីន ៖ ឥឡូវនាងឯងអាយុចាស់ អត់ទាន់មានប្តីទេ គេមានគំនិត គេរកប្តីឲ្យយើង ។

កា ៖ ខ្ញុំទើបអាយុ២២ ឆាប់ចាស់ម៉េច(សើច) ។

ភីន ៖ អត់ទេ ខ្ញុំឧទាហរណ៍ៗសម័យនោះ សម័យឥឡូវនេះអ្នកណារកប្ដីឲ្យ មើលខ្ញុំសួរតិច ។

កា ៖ អត់មានអ្នកណារកឲ្យទេ ទាល់តែគេស្រឡាញ់បានគេចូល(សើច) ។

ភីន ៖ នែក! វាពិបាកចឹង គេយល់ចិត្តមនុស្សដែរតើ មិនមែនគេធ្វើទាំងបំពានទេ នាងឯងគតទៅចាស់ហើយគេរកឲ្យ តែក្មេងគេមានច្បាប់គេកាលនោះខ្ញុំប្រាប់តិចចុះ អត់មានការផ្ដេសផ្ដាស់ បន្ទំដូចឥឡូវបានទេ។ ក្រោមពីអាយុ២៥ នារីគឺមិនបានការទេ។ ប្រុសអាយុ៣០ ក៏មិនបានការទេ គេថាការក្មេងៗមនុស្សវាខូចសុខភាព គេនិយាយរឿងសុខភាពដែលកាលនោះ ។ បើឯងឥឡូវនេះ អាយុ១០ឆ្នាំរត់ទៅការអីទៅនេះអស់ហើយ ។ ហើយមើលទៅយូរទៅកូនអត់មានផ្ទឹមកើតទេ តូចទៅៗដូចកូនកណ្ដុរ ក្រឡាតចឹង ។ ចឹងឯង កាលនឹងគេរៀបរបៀបចឹងទេកាលនោះ អត់មានឲ្យអ្នកណានៅមេម៉ាយប្ដី-ប្រពន្ធអីអត់មានទេ ។

កា ៖ កុំឲ្យកំណើនប្រជាជន ធ្វើចឹងកុំឲ្យអត់មានប្រជាជន?

ភីន ៖ គេខំបង្កើនកាលនោះ ។

កា ៖ ព្រោះអីប្រជាជនយើងតិចដែរ?

ភ៉ន ៖ ប្រជាជនយើង៨លានទេ ច្បាំងជាមួយអាមេរិចផង ច្បាំងជាមួយយួនផង ដូច្នេះវាងាប់ចង់ហើយ ។ ដូច្នេះ គេអត់ទប់ស្កាត់រឿងកំណើតប្រជាជនទេ គេឲ្យកើត ។ ហើយវិធីគេមានបេះទៀត មនុស្សធំដូចគ្នា អត់ឲ្យយកគ្នានេះទេ បើមានអាមួយតូចអាមួយធំ អាមួយធំអាមួយតូច ។

កា ៖ យកកុំឲ្យកូនមកល្អ ។

ភីន ៖ កូនមក អត់ទេ គេអត់ធ្វើចឹង ។

កា ៖ អ្នកណាស្អាត?

ភីន ៖ ដែលប៉ះស្អាតទាំងពីរនាក់ភាគតិចណាស់ ព្រោះគេរៀបរយចឹង គេមិនទាញដាក់ៗទេ ។

កា ៖ គេឲ្យអនាគតកូនមកស្អាត?

ភីន ៖ បាទ! បើនាងឯងជឿ មិនជឿខ្ញុំអត់ទៅ ប៉ុនខ្ញុំនិយាយឲ្យដឹងពុកាលសម័យនឹង ។

កា ៖ បើខ្ញុំអត់ដឹងផង ទាល់តែសួរអ៊ំ ។ ចុះអ៊ំគិតថានៅសម័យនោះ យើងមានភាពស្មើគ្នាទាំងអស់គ្នា?

ភីន ៖ សម័យហ្នឹង អឺ!អត់មានសុំទាន អត់មានក្មេងជក់ម៉ា អត់មានការផាររបេះទេ អត់មានទេ ។ ឥឡូវដូចប៉ាប្អូនឯងធ្វើអីអត់ទាន់កើត គេឲ្យទៅធ្វើដីដាក់ស្រែអីចឹងទៅ ហើយដីមានទិញពីណាមកបាន គ្មានអ្នកណាលក់ឲ្យយើង អត់ទេ សម័យនោះអត់មានទេ ។

កា ៖ ធ្វើខ្លួនឯង?

ភីន ៖ ធ្វើខ្លួនឯងទាំងអស់ កំប្លោកនៅបឹងកន្ទែងម៉ុផ្ទះឯងអានឹងខ្ញាវមកយកធ្វើជីអស់ហើយកំផ្លោកវែកមកកគរមិនសល់ទេ ជីដំបូក ធ្វើជីដែរ ។

កា ៖ ចឹងឥឡូវពូមានជំនឿលើសាសនាច្រើនជាមុន ឬម៉េចដែរ?

ភីន ៖ ហឺ! ធ្វើបុណ្យនឹងគេតើឥឡូវ សាសនាព្រះពុទ្ធយើង ។

កា ៖ ជឿលើកម្មផលច្រើន?

ភីន ៖ ហ៎! អញមិនជឿទេ កម្មផលខ្មោចអី បើអញមិនរកអត់ ។

កា ៖ ត្រូវ?

ភីន ៖ អ! យល់ព្រមដែរ អត់ទេវើយ កម្មផលណាអត់មានចូលបាន បើយើងមិនរកអត់ហើយ ។ កុំឃើញ ហ៊ុន សែន គាត់សំពះលោក គាត់គិតកម្មផល មិនមែនទេ បើគាត់មិនរកអត់បានធ្វើនាយកទេ ។ អត់មានលោកឲ្យធ្វើនាយកបានទេ ។

កា ៖ ចឹងកាលនៅសម័យ៣ឆ្នាំ អ៊ំមានតួនាទីអីដែរ?

ភីន ៖ ធ្វើទាហាន អត់មានធ្វើអី ។

កា ៖ ទាហានផ្នែកអីគេ?

ភីន ៖ យី!ទាហាន កាលនឹងទាហានមិនច្បាំង ។ នេះនិយាយហួសហើយ ទាហានអញធ្វើពីឆ្នាំ៧០ មកទេ សម័យ៣ឆ្នាំនៅក្រោយសុទ្ធហើយពិការហើយ បើអ៊ំពិការតាំងពី៧៤នោះ ។ ច្បាំងបានតែប៉ុន្មានឆ្នាំទេ ។

កា ៖ កាលនឹងបានទៅច្បាំងជាមួយលន់ នល់ទេ?

ភីន ៖ អឺ! ចប់លន់ នល់ទៅចប់ដែរ ។

កា ៖ ចឹងចប់ពីលន់ នល់ អ៊ំគេឲ្យធ្វើអី?

ភីន ៖ នៅផ្ទះ នៅចឹងទៅ នៅជាមួយសហករណ៍អីគេចឹងទៅ ។

កា ៖ គេឲ្យធ្វើអី?

ភីន ៖ ធ្វើអី ធ្វើស្រែធ្វើចំការដូចយើងឥឡូវនេះចឹង បើយើងធ្វើអីមិនកើត ចុះស្រែមិនកើតគេឲ្យនៅធ្វើអីមើលគោមើលអីឲ្យគេទៅ ។

កា ៖ គេលែងឲ្យធ្វើទាហានទៀតហើយ?

ភីន ៖ ទេ! អ្នកណាធ្វើអីបើយើងពិការហើយ ។

កា ៖ ចឹងទាហានបានត្រឹមដល់ឆ្នាំ៧៤?

ភីន ៖ អឺ! ៧៤ ។

កា ៖ សុទ្ធតែអ្នកតស៊ូដើម្បីជាតិហើយ បាត់បង់ជើងអី ។

ភីន ៖ ហឺ! ជាតិសុទ្ធ ឥឡូវនាងឯងមើលគិតកាលនឹងចុះ អត់មានតស៊ូដើម្បីបុគ្គលណាទេ អត់មានទេ គេគិតរឿងជាតិ រឿងទឹកដី គេអត់មានបង្ហាញអីច្រើនទេ គេបង្រៀនយើងតែប៉ុននឹងការពារជាតិការពារទឹកដី ។ រឿងទឹកដីនេះហើយដែលងាប់មនុស្សច្រើន អ៊ំប្រាប់ បើសម័យគេមិនសូវគិតទឹកដី អត់ងាប់ទេ ។ ឥឡូវក្លាយឯងជឿទៅ ជំណាយកអីយកទៅ អត់ងាប់ទេមនុស្ស គ្មានងាប់អី ។ ប៉ុនគ្រាន់នាងឯង អត់ដីនៅ ប៉ុននឹងឯង ។ ប៉ានាងឯងអត់ដីនៅកណ្តាលបឹងកក់ បឹងសង្កែនឹងទៅ ។

កា ៖ ដូះខ្ញុំភ្ញៀងមកបេះអីទឹកលិចដែរតើ ។

ភីន ៖ លិច ។

កា ៖ ចឹងខាងណាអ្នកដាក់បញ្ជាឲ្យអ៊ំទៅធ្វើស្រែធ្វើចំការ? សហករណ៍?

ភីន ៖ អឺ! សហករណ៍កាលនឹងគេមានសហករណ៍ ។

កា ៖ ប៉ុន្តែអ៊ំនៅក្នុងកងអីគេដែរ?

ភីន ៖ យី! នៅសហករណ៍ធម្មតា មានទៅកងស្ទួ គេមានកងចល័តដែលកាលនោះ ប៉ុនយើងនៅពិការទៅនៅចល័តកើតអាណាឲ្យទៅធ្វើចល័តអី ។

កា ៖ អ!ចល័ត មើលមានកងអីខ្លះក្នុងនឹង?

ភីន ៖ មានកងចល័តៗគេអ្នក ដូចនាងឯងឥឡូវខ្ញុំប្រៀបធៀប ដូចនាងឯងកម្លាំងលេខ១ កម្លាំងល្អជាងគេ គេដាក់កម្លាំងលេខ១អានឹងនៅកងចល័តហើយ ។ អាពួកអន់ៗនៅតាមសហករណ៍ធ្វើអីមិនកើត ។ គេរៀបរយមនុស្សបឹង ឲ្យស្មើគ្នា គ្មានអ្នកណាជិះឡាន អ្នកណាដើរសុំទានអត់មានទេ ។

កា ៖ ប៉ុន្តែខ្ញុំសរសើរប្រជាជននៅនេះ ទោះបីគាត់ពិការម៉េចក៏ដោយ ក៏អត់មានអ្នកណាគេទៅសុំទាន?

ភីន ៖ អត់ទៅសុំទាន នាងឯងគួចចានប្រវត្តិសាស្ត្រឲ្យដង កុំបេះដើរនិយាយខុសពីរឿងពិត ខ្លះនឹងអត់មានសុំទានម្នាក់ក៏អត់ ។

កា ៖ មែនតើ អត់មានអ្នកណាសុំទានទេនៅនេះ ទោះបីគាត់ពិការ ។

ភីន ៖ អត់មានអីហូប ព្រលឹមឡើងទៅមើលដើរចូលព្រៃរកដំឡូងរកអីហូបអស់ គ្មានសុំទានគេ តែឃើញមានអ្នកសុំទានមើលមានទេ បើមាន១ ឬមាន២ ទៅសួរមើលទៅនោះមកពីណាអត់មានទេនៅនេះ ។

កា ៖ ខេត្តផ្សេងៗ បើនៅនេះអត់មាន?

ភីន ៖ បាទ! គ្មានទេ ខ្មាស់ធ៊ំងរឿងសុំទានគេខ្មាស់ ត្រង់ពីមុនគេប្រដៃប្រដៅ ។

កា ៖ ទោះបីជាគាត់ពិការម៉េចក៏ដោយ ក៏គាត់ខំប្រឹងធ្វើអីផ្សេង ធ្វើចំការ ចូលព្រៃបេះ ។

ភីន ៖ ខ្មាស់គេត្រង់ យើងនៅចាំបានថាគេបង្រៀនឲ្យខំធ្វើ ខំរកខ្លួនឯងចិញ្ចឹមជីវិត ។ គេនិយាយពាក្យមួយបេះ អត្តាហិ អត្តានោនាថោ ។ ដែលពួគេនិយាយពាក្យ?

កា ៖ ធ្លាប់ឮ ។

ភីន ៖ អត្តាហិ អត្តានោនាថោ ខ្លួនទីពឹងខ្លួន អត់មានពឹងអ្នកណារស់បានទេ ។ ដូចប៉ានាងឯងចឹងគាត់ខំណាស់ គ្មានពឹងអ្នកណាបានទេ អត់ទេ មានតែពឹងខ្លួនយើងៗមានប៉ុន្មានហូបប៉ុននឹង បើមិនពឹងគេសោះ គឺមិនមានទេមិនបាច់ពឹង បើគេឲ្យយក មានអង្គការណាគេមកអភិវឌ្ឍន៍មកធ្វើអីឲ្យយក ។ ប៉ុនបើមានគំនិតទៅដើរសុំគេមិនមានទេ ។ គំនិតខ្ញុំត្រង់ចឹងឯង អត់ងាយសុំគេទេ ។

កា ៖ ចឹងល្អតើអ៊ំ?

ភីន ៖ អឺ! អត់ងាយទេ ។

កា ៖ បើនៅភ្នំពេញវិញ មិនដឹងមកពីណា ។

ភីន ៖ អើ! បើនាងឯងមានស្គាល់មនុស្សអត់ ល្មមៗអត់ធ្វើអីដេកតែស៊ីនឹង តាំងគិតអីមិនលេចតាំងសុំទានគេហើយ ។ អានឹងមនុស្សចឹងអត់ការងារធ្វើ រដ្ឋាភិបាលត្រួតត្រាគាត់អត់បានទេ ទៅនៅភូមិនេះក៏គ្មានឈ្មោះ ទៅនៅភូមិនោះក៏គ្មានឈ្មោះ ដូច្នេះនៅក្រោមស្ពានវាទៅយាប់ជាងអាពួកខ្មែរក្រហមចាស់នឹងទៅទៀត យ៉ាប់និយាយណាស់ ។

កា ៖ ចុះអ៊ំកាលនោះ អ៊ំគិតថា ខ្លួនឯងជាជនរងគ្រោះដែរអត់ទេ?

ភីន ៖ ហ៊េ! អញមិនគិតចឹងទេ ។

កា ៖ ជាអ្វី?

ភីន ៖ អឺ! ជាជនធម្មតាចឹងទៅ យើងធ្វើជនរងគ្រោះអី បងប្អូនខ្ញុំស្លាប់អស់ច្រើនមែន ប៉ុនអត់ចាត់ទុកជាជនរងគ្រោះទេ ។

កា ៖ ជាស្នេហាជាតិសុទ្ធ?

ភីន ៖ អឺ! ចាត់ទុកចឹងព្រោះងាប់ដោយសារគេសម្លាប់ដែរ មិនមែនសញ្ជាតិខ្លួនឯងសម្លាប់ទៀតជាតិបរទេសសម្លាប់ទៀត ។

កា ៖ ចឹងកាលនោះអ៊ំអន់ចិត្តដែលរដ្ឋាភិបាលឲ្យវៀតណាមចូល?

ភីន ៖ ទេ! អានឹងអន់ចិត្តមួយសារហើយ អាមួយទៀតអន់ចិត្តនឹងកាលគេធ្វើបាបយើងមុន ។

កា ៖ មួយទៀតនៅណា?

ភីន ៖ មួយទៀតអាមេរិច ដែលឲ្យលុយនាងឯងមកនេះ ។

កា ៖ មានអាមេរិចណាឲ្យលុយខ្ញុំមក(សើច) ។ មិនមែនអាមេរិចណាអ៊ំ ។

ភីន ៖ ឥឡូវអ៊ំប្រាប់ ក្មួយឯងគេឲ្យលុយហូបបាយ ឲ្យលុយដេករាល់ថ្ងៃនឹង គឺលុយអាមេរិចសុទ្ធហើយ ។

កា ៖ មានណាសាលាខ្ញុំអាឡឺម៉ង់នឹង?

ភីន ៖ អាឡឺម៉ង់ក៏អាមេរិចឲ្យដែរ អាឡឺម៉ង់កូនអាមេរិចទេ អាមេរិចឪគាត់ ។ អាមេរិចគេឲ្យលុយមកសម្រាប់កាត់ទោសខ្មែរក្រហម ដូច្នេះខ្ញុំចង់និយាយតិចថា មនុស្សយើងអ្នកចេះ ប៉ុននាងឯងកុំរៀនអីចេះពេកនាំគេសម្លាប់ចោល ។ តែអាណាចេះខ្លាំង គឺត្រូវតែទៅហើយអត់នៅទេ។ ឥឡូវជំនាន់ណា នាងឯងរៀន អាចារ្យស្វា, ពោធិ៍កំបោរ, ហែម ជៀវ, ឯណា ។

កា ៖ ទៅទាំងអស់?

ភីន ៖ ទៅទាំងអស់ ឲ្យតែអ្នកស្នេហាជាតិ ថាស្រឡាញ់ជាត គឺងាប់ហើយ ។ ហើយងាប់ដោយសារគេចោទទៀត ថាឯងក្បត់ជាតិសម្លាប់មនុស្សចេះចុះក្នុងស្រុកសុទ្ធតែមានរឿងចិនហើយ ឥឡូវចូលដល់ ប៉ុល ពត យើងដឹងមើលឃើញទេ ។ នាងឯងទៅមើលឆ្អឹងកន្លែងផ្នូរនោះ ស្អប់ ប៉ុល ពត មួយសកលលោក ប៉ុនទៅមើលឆ្អឹង ប៉ុល ពតមានឆ្អឹងនៅសល់មួយអត់ សល់ប៉ុនក្រចកដៃអត់ ។ អត់មានសល់ទេ កកាយយកទាំងអស់មិនមែនខ្មែរយើងទេ កកាយ ពួកអាប្រមុះវែងនឹងទៅកកាយ ។

កា ៖ យកទៅធ្វើអី?

ភីន ៖ យកទៅ អាណាបានធំអរទៅ អាណាបានតូចអរតាមតូចទៅ ។

កា ៖ គេយកធ្វើអី?

ភីន ៖ អត់ដឹងទេ ។ អញខ្ជិលប្រាប់ដែរនឹង ។

កា ៖ យកធ្វើអី? ខ្ញុំធ្លាប់ទៅកន្លែងគាត់ដែរ មានរោងមួយ ។

ភីន ៖ ដែលឃើញ អឺ!រោងកញ្ចក់មួយ ដែលបានខ្ទេះមើលធ្យូងនឹង?

កា ៖ អត់មានអីផងនឹង?

ភីន ៖ អត់មានអីទេ អាប្រមុះវែងខ្ទេះមើលអស់ហើយ ។

កា ៖ យកធ្វើអី?

ភីន ៖ គេយកទៅពិនិត្យ ស្រុកគេមានម៉ាស៊ីនឆុះ ម៉ាស៊ីនថតឆ្អឹង ។

កា ៖ មើលចឹងដើម្បីអី?

ភីន ៖ មើលខួរក្បាលរបស់មនុស្សនឹង វាយ៉ាងម៉េចវាខុសគេ ម្យ៉ាងគេចោទថាខុសគេរឿងសម្លាប់ ប៉ុនម្យ៉ាងទៀតមនុស្សនេះប្រើមនុស្សអត់ចាយលុយ សម័យនោះអត់មានលុយប្រាក់ខែទេ អ៊ំប្រាប់តិច សួរឪឯងមើលវែកដីដំបូកដែលមានលុយទេអត់ទេ គេឲ្យតែបាយហូប ហើយរឿងអីធ្វើសង្គ្រាមឈ្នះគេនឹង ។ គេខឹងចឹង គេយកក្បាលទៅពិនិត្យមើលវាក្បាលអីខុសគេ យកអស់ហើយ នាងឯងមិនបាច់មកក្បែរ មកលើកក្រោយទៅមើល ។

កា ៖ ខ្ញុំធ្លាប់ទៅមើលហើយ ប៉ុន្តែអត់មានឃើញអី?

ភីន ៖ គ្មានទេ ខ្មែរយកអស់ហើយ ។

កា ៖ មានរោងមួយ ដូះរៀងពូនតិចទេ ។

ភីន ៖ ហ៊ើ! ពូនាមៗទេ ប៉ុនខ្មែរយកអស់ហើយឆ្អឹង ។ ឥឡូវនេះនាងឯងយកឆ្អឹងគោ២ដុំ ៣ដុំ ទៅដាក់ ១ខែក្រោយមកមើលទៀតបើនៅ យកខ្មោចបាត់អស់ មិនសល់ទេ អស់ឆ្អឹងមនុស្សហើយ យកឆ្អឹងក្របីដាក់ក៏យកដែរលើកនេះ វាចឹង ។

កា ៖ ចឹងសម្រាប់អ៊ំវិញ កាលដែលយើងបង្កើតសាលាក្តីខ្មែរក្រហមអីមក អត់ប្រយោជន៍?

ភីន ៖ ហ៊ា!

កា ៖ គេបង្កើតសាលាក្តីខ្មែរក្រហម តុលាការ?

ភីន ៖ ទេ! គេបង្កើតៗទៅចំពោះពួកអ្នកស្អប់ៗនៅអាមេរិចទាំងអស់ ឥឡូវខ្ញុំប្រាប់នាងឯង អ្នកស្អប់មកពីនឹងទាំងអស់ អ្នកមិនសូវស្អប់ទេនៅស្រុកខ្មែរ ។ បើតាមអ្នកស្រុកខ្មែរអត់មានកាត់ទោសចឹងទេ ប៉ុនអ្នកនៅអាមេរិចគេឲ្យលុយមកទាំងបាវៗ ដូច្នេះគេបង្ខំចិត្តធ្វើហើយ ដើម្បីចិញ្ចឹមក្រុមគ្រួសារគេដែរ សុខចិត្តឲ្យងាប់អាមនុស្សកញ្ចាស់២-៣នាក់ ងាប់ទៅ បានលុយចិញ្ចឹមគ្រួសារគេ ។

កា ៖ ចឹងអ៊ំគិតថាអយុត្តិធម៌សម្រាប់អ្នកដែលត្រូវគេចាប់នឹង?

ភីន ៖ ហ៊ា!

កា ៖ អ៊ំគិតថា អ៊ំចាស់ៗដែលគេចាប់យកទៅនឹង វាអយុត្តិធម៌សម្រាប់គាត់?

ភីន ៖ អឺ! អានឹងវាចឹងឯង ព្រោះបើសម្រាប់រឿងគេវាអយុត្តិធម៌រឿងគេ ប៉ុនចំពោះខ្ញុំអយុត្តិធម៌ចំពោះខ្ញុំដែរទេ ។

កា ៖ អត់មានយុត្តិធម៌?

ភីន ៖ មិនមានទេ បងប្អូនខ្ញុំស្លាប់ដោយសារគេសម្លាប់ដែរគ្មានអ្នកណាទៅកាត់ទោសអត់ផង ។ ខ្ញុំបើយកពួកបើកបេ៥២មកកាត់ទោស បើយកពួកបើករថក្រោះមកកិនខ្មែរងាប់អស់ មកកាត់ទោសអានឹងយុត្តិធម៌ចំពោះខ្ញុំផងដែរ ។ អានោះយុត្តិធម៌ចំពោះអ្នកនៅអាមេរិចទេ ធ្វើ

នឹងនោះ ព្រោះអាមេរិចអ្នកឲ្យលុយ ។ ខ្ញុំអត់ដេរថាគេទេ ប៉ុន្តែខ្ញុំដឹងថាគេអ្នកឲ្យ គេអ្នកខឹង ខ្មែរៗអ្នកឈ្នះគេប៉ុននឹង ។ ពុកឯងទំរែកដីដំបូក ម៉េចឈ្នះគេ ឯងលបស្នូរស្ងាត់ៗ ។ មានអ៊ុំមួយចាស់ និយាយថាពុកឯងឈ្នះអាមេរិចកាំង ឈ្នះម៉េចវិញ ពុកឯងរែកដីដំបូកសោះ រួមគ្នា អានឹងនិយាយរួមគ្នា ។ អាអ្នករែកដីដំបូកក៏ឈ្នះ អាអ្នកធ្វើអីដូចសម្តេច ហ៊ុន សែន គាត់ដាក់ឈ្នះៗ នយោបាយឈ្នះៗ អ្នកណាធ្វើអីក៏ឈ្នះៗតាមការងាររបស់ខ្លួន ។ សម័យនោះក៏ចឹងដែរ ។

កា : ចុះដែរតាមដានមើលព័ត៌មានអីពីសាលាក្តីខ្មែរក្រហម?

ភីន : មើល អ៊ុំមើល ហ៉ើ! អ៊ុំអត់មានទូរទស្សន៍ អញស្តាប់វិទ្យុផ្សាយ មានទូរទស្សន៍ឲ្យអ៊ុំមួយមកអ៊ុំទុកគ្រាន់មើល ។

កា : មនុស្សមិនទាន់មានការងារធ្វើផង(សើច) ។

ភីន : អើយ! ចៅឯងយ៉ាប់ណាស់ ខំរៀនឲ្យបានថ្នាក់ខ្ពស់ ។

កា : ចឹងអ៊ុំគិតថា ។ និយាយទៅខ្ញុំធ្លាប់ឮអ្នកខ្លះគាត់និយាយថា តាមខ្ញុំនៅក្មេងអត់ដែលដឹងអី គេថា ប៉ុល ពត នៅទួលស្លែងថាសម្លាប់មនុស្សអីចឹង ។

ភ៉ន : តា ឌុច ។

កា : ហ្នឹងហើយ អ្នកខ្លះទៀតថាវៀតណាមមកក្លែងបន្លំមកក្រោយ ពីមុនមកអត់មានចឹងទេ ពេលវៀតណាមចូលមកបានឃើញចឹង ។

ភីន : ឥឡូវបើទុកខ្ញុំនិយាយរឿងយួន ក៏នាងឯងមិនជឿ ។

កា : អត់ទេ អ៊ំឯងនិយាយមក ខ្ញុំចង់ស្តាប់ ។

ភីន : ចង់តែស្តាប់ ។

កា : ស្តាប់ខ្ញុំយកមកពិចារណាដែរ ។

ភីន : ត្រង់ជឿមិនជឿទេ ។

កា : ហ៉ើ! មិនត្រូវដែរ អ៊ុំនិយាយមកនេះ សួរគ្នាច្រើនចឹង ។

ភីន : ឥឡូវនេះខ្ញុំសួរនាងឯងវិញ នាងឯងរៀនបានខ្ពស់ ដឹងប្រវត្តិសាស្ត្រនិយាយប្រវត្តិសាស្ត្រខ្មែរយើងអ្នកណាខ្លះឈ្លានពានដុំវិញ?

កា : ថៃ យួន ២នឹងច្រើនជាងគេ ។

ភីន : អឺ! តែ២នឹងទេ ឡាវមិនដែលមានទេ អត់មានទេ ។ ហើយអ៊ុំនៅព្រំដែនយួន ផ្ទះជាប់ជិតព្រំដែនស្គាល់ណាស់ មិនបាច់ថាមកសម្លាប់ខ្មែរដោយបាញ់គ្រាប់កាំភ្លើងនាងឯង ពីរដ្ឋប្រហារលន់ នល ហើយ យួនមិនមកជួយវៃលន់ នល់ យួនខាងត្បូងនឹងគេត្រូវជាមួយ

លន់ នល់ៗខ្មែរយើងទេ មិនមែនយួនទេ។ គេមកជួយយើងទេ ឥឡូវនាងឯងផ្ទះធំចេះមានស្អីនៅលើផ្ទះ មនុស្សគេអត់សម្លាប់ទេ ប៉ុនរបស់នៅលើផ្ទះ ខោអាវ សារុងសូត្រ អាវសូត្រ របស់ចាស់ៗដែលយើងកំណត់ថាមានតម្លៃទុក វាយកទៅដូតរថក្រោះវាអស់ ហើយដូតហើយដាក់រថក្រោះកិនចោល ចានឆ្នាំង យើងថ្មីៗទុកសម្រាប់ក្រុមគ្រួសារយើង ភ្ញៀវអីខ្ទេចអស់ហើយ។ ស្រូវស្រែយើងកំពុងសាបនឹង រថក្រោះវាទៅចតចោលកណ្ដាល ចឹងមកអស់រលីងមួយស្រែ។ ទៅដល់ស្រែស្រូវទៀតនោះទៀត ឃើញស្រូវកំពុងបែកគុម្ព រថក្រោះវាចត អស់រលីង។ សម្លាប់ខ្មែរដោយវិធីនេះ យួនគេសប់យើងណាស់ គេអត់ស្រឡាញ់ទេ ព្រោះបើគេមិនស្អប់យើងគេយកដីយើងម៉េចបាន។

កា : ចឹងគេកាត់ទោសមេដឹកនាំធំៗអី អ៊ំអត់សប្បាយចិត្តទេនោះ?

ភីន : ទេ! រឿងគេកាត់ៗទៅ អ៊ំអត់មានទៅខ្វល់ខ្វាយអីជាមួយគេទេ ព្រោះមនុស្សចាស់ហើយ អត់កាត់ក៏ស្លាប់ដែរ។ នោះអ្នកត្រូវហៅគេកាត់នឹង ស្លាប់មុនអ្នកកាត់ទៀត ឃើញទេ។ ស្ដាប់ទាន់ទេពាក្យមិញ។ តាអីស្លាប់ថ្ងៃមុននេះ វណ្ណាត នឹងហើយគាត់ខឹងៗខ្លាំងពេកស្លាប់ខ្លួនឯង វាមួរម៉ៅក្នុងក្បាលដោះស្រាយអីអត់ចេញទេ គេរកយុត្តិធម៌ឲ្យគាត់មិនឃើញយូរពេក ទៅហើយ។ នៅប៉ុន្មាននាក់ទៀត មិនស្រួលអត់បានកាត់ទោសតាៗនឹងចប់ផង គាត់វិលវល់នឹងស្នេហាខ្លួនគាត់ខ្លាំងពេក អាយុខ្លី។ ឲ្យតែដេកមិនលក់ បក់មិនល្ហើយរាល់ថ្ងៃៗ អត់អាយុវែងទេ មនុស្ស។ និយាយខ្លីប៉ុននឹងអត់និយាយអីទេ និយាយតាមវិទ្យាសាស្ត្រ ចឹងម៉ងទៅ អាណាគេដេកលក់ស្រួល អាណាគេមិនគិតច្រើនអី អាយុវែងណាស់។ នេះប្រហែលតា ឌុច អាយុ១០០មិនងាប់ផងក្នុងគុក។ គាត់លែងគិតអីហើយ ប៉ែលម៉ោង ចាស់ៗគេនិយាយថាប៉ែម៉ោង លែងគិតអីហើយ។ គិតតែហូបបាយដេកៗចាំតែថ្ងៃងាប់ អានឹងអត់ងាយងាប់ទេ រស់។ តែអាខ្វល់ខ្វាយពីរឿងគេជំនួសខ្លួនឯងអានឹងទៅហើយ អត់នៅយូរទេ កុំគិតច្រើន។ ខ្ញុំអត់គិតអីច្រើនទេ។

កា : ចឹងអ៊ំអត់ចង់គេកាត់ទោសលើសពីអ៊ំចាស់ៗប៉ុន្មាននាក់នឹង នៅសាលាក្ដីដែរ?

ភីន : ហ៎! ច្បាប់ បើនិយាយរឿងច្បាប់អត់មានទេ។ នាងឯងដឹងទេច្បាប់ គេកាត់តែអាដឹកនាំខ្ពស់បំផុត និងអាទទួលខុសត្រូវខ្ពស់បំផុត។ ប៉ុនអាអ្នកអស់នឹងជាប់គុកអស់ហើយនឹង គ្មានអ្នកណានៅ អាក្រោមៗនេះ បើប្រៀបធៀបដូចប៉ានាងឯង ពួកវែកដីដំបូក ពួកវែកអីនឹង ទៅហៅគ្នាងាប់អន្តរធាន កាត់ទាំងអស់ហៅទាំងពុកនាងឯងទៅកាត់ផង ខ្មែរក្រហមទាំងអស់សម័យនោះ មេឃរលំ កិនអ្នកណាមិនយកដើងទ្រ។ ហើយឥឡូវនេះរបបសម្ដេច ហ៊ុន សែន អ្នកណាមិននៅជាមួយរបបសម្ដេច ហ៊ុន សែន នាងឯងចៀសផុត។ អត់ទៅសម

រង្សី អត់ទៅអីទេ នៅជាមួយ ហ៊ុន សែន ហើយ។ ចឹងឯង គ្មានអ្នកណាគេចង់ទេ
ចោទថាគ្នាខ្មែរក្រហមទាំងអស់ ងាប់ម៉ង។

កា : ចឹងបានន័យថាប្រសិនបើកាត់ទោសថែមទៀត គួរតែកាត់ទាំងអស់?

ភីន : ទាំងអស់ទៅ នោះកាត់ទោសទាំងអស់មកចង់កាត់ទោសឲ្យទោសយើងផង ម៉ែឪវាអត់មាន នៅស្រុកខ្មែរដែរ អត់មាននៅអាមេរិចទេ នៅអាមេរិចតែវាទេ។

កា : អ្នកណាគេ?

ភីន : ពួកនៅសាលាក្តី នាងឯងស្គាល់អត់សុទ្ធតែមកពីអាមេរិចមកឈរឈ្មោះ។ ស្គាល់ សេង ធារី និយាយខ្មែរមិនច្បាស់ផង ហើយចោទថាគេសម្លាប់ឪពុកម្តាយគាត់ ដឹងស្លាប់ដោយសាររឿងអី ជំនាន់នឹងកើតរោគស្វាយ ប្រមេះ ច្រើនផង ងាប់ដោយសារអានឹងក៏មិនដឹង ដោយសារគេមានរឿងអីអានឹងចាញ់គេចោទទៅឲ្យងាប់ចឹងទៅ សេង ធារី។

កា : គាត់និយាយខ្មែរអត់ច្បាស់មែន។

ភីន : អត់ច្បាស់ទេ នាងឯងមិនមែនមនុស្សខ្មែរទេ មកពីអាមេរិចសុទ្ធសាធម៉ង តែគេធ្វើម៉េចធ្វើទៅ ខ្ញុំអត់មានទៅខាយាំងទោះបីឪពុកម្តាយយើងក៏ខាយាំងគេមិនបាន បើគេចាប់យកទៅហើយ បើគេចោទចឹងហើយ តាមមួយដំណើរគាត់ទៅ។

កា : ចឹងសម្រាបពេលសព្វថ្ងៃវិញ អ៊ុំធ្វើតាមអ្វីដែលរដ្ឋាភិបាលដាក់មកទាំងអស់?

ភីន : អឺ! ហ្នឹងហើយ អត់មានខ្វល់ខ្វាយអី ថាអានេះល្អ អានោះអាក្រក់ អ៊ុំអត់មានទេ ឲ្យតែអ្នកដឹកនាំប្រទេស គឺល្អទាំងអស់ ហើយអ្នកដឹកនាំប្រទេសត្រូវតែខុសចឹងហើយ កុំថាសម្តេច ហ៊ុន សែន កុំថា ប៉ុល ពត កុំថាណានោះ ឲ្យចេញពីដឹកនាំគឺខុសមងមនុស្ស អត់ចេះត្រូវទេ។ ហើយអ្នកដឹកនាំប្រទេស គឺគេត្រួតមនុស្សហើយ គេមិនត្រួតសត្វឆ្កែទេ ដូច្នេះមនុស្សណាធ្វើតាមគេល្អ មនុស្សណាមិនធ្វើតាម ដូចអ៊ុំនិយាយថាអាក្រក់ចឹងគេចាប់ដាក់គុកដាក់ច្រវាក់ឥឡូវនឹង។ គិតមើលដូចសព្វថ្ងៃ គេមិនឲ្យឯងទៅឆក់ទៅលួច ឯងទៅឆក់ទៅលួច គេមានភ្នាក់ងារគេចាប់ទៅដាក់គុកបាត់កាត់ទោសឯងប៉ុន្មានឆ្នាំៗ។ គ្រាន់គេអត់សម្លាប់បាញ់នឹងគ្រាប់កាំភ្លើងទេ គុកនឹងគ្រាប់កាំភ្លើងនឹងងាប់ដូចគ្នា ប៉ុនអាមួយងាប់ក្នុងគុក ប៉ុនអាមួយងាប់នឹងគ្រាប់កាំភ្លើង ងាប់នឹងគេវៃចឹងទៅ ប៉ុននឹងទេ។ ប៉ុនដឹងថាមានទោស គឺដឹងថាជីវិតខ្ញីហើយ កុំធ្វើឲ្យខុស តែប៉ុននឹងទេ សម័យនោះស្លាប់ថាឯងកុំលួចមាន់ស៊ីតែឯងស៊ីៗមានគ្នា ចែកគេហូបផង។ អត់ទេ វាឃ្លានពេក វាស៊ីតែឯងងាប់ហើយ អត់មានគេជំនុំជម្រះទេ គេថាគុកអត់ជញ្ជាំងកាលនោះ គ្មានអ្នកណាមានគុកអីចេះមនុស្សរាប់ម៉ឺន។

កា : តែអ៊ុំបានហូបចុកអីគ្រប់គ្រាន់?

ភីន : កាលនោះ?

កា : ចា៎!

ភីន : អ៊ំនិយាយថាមិនប្រឆាំងគេ ត្រង់ថាយើងស៊ូម៉េង អារឿងរបបនឹងរបបអត់ម៉េង គ្មានអ្នកណាជួយទើបចេញពីសង្គ្រាម នាងឯងអ្នកណាជួយ ។ ឥឡូវអ៊ំប្រាប់តិច សង្គ្រាម ឥឡូវជំនាន់សម្តេច ហ៊ុន សែន គាត់សុំគេតាំងពីសូវៀត សុំគេតាំងពីវៀតណាម សុំគេតាំងពីអឺរ៉ុបខាងកើត ។ ប៉ុន្មានប្រទេសអឺរ៉ុបខាងកើត ស្គាល់ទេ?

កា : ២០ប៉ុន្មានប្រទេស ។

ភីន : ១៨ប្រទេស អឺរ៉ុបខាងកើត បើអឺរ៉ុបខាងលិចច្រើន សម្តេច ហ៊ុន សែន សុំពួកខាងកើតទេ ខាងនឹងត្រូវកុម្មុយនីស ។ គាត់សុំគេបានមកចឹង កាលខ្មែរក្រហមមានតែចិនមួយទេជួយចិញ្ចឹម ហើយគេប្រទេសមួយមកចិញ្ចឹមប្រទេសយើងមួយដែរ អត់គ្រប់ទេ ។ ហើយយើងខំធ្វើទាំងអស់គ្នា ដូចប៉ានាងឯងចឹង គេឲ្យទៅវែកដីដំបូក វែកដីអីដើម្បីធ្វើស្រែហើយធ្វើស្រែដើម្បីហូបខ្លួន ដូច្នេះអត់មានអ្នកណាទំនេរ ដូច្នេះមនុស្សនៅភ្នំពេញនឹងគេចោទថាគេជម្លៀសមនុស្សភ្នំពេញៗ ព្រោះមនុស្សនឹងអត់ធ្វើស្រែសោះ គេយកទៅឲ្យជួយធ្វើស្រែធ្វើអីហូបនឹង គ្មានអង្ករទិញណាដូចមុនបាន ហូបបាយសហករណ៍នឹង ។ អ៊ំនៅទាហាន ១ពេលគេឲ្យហូបអង្ករមួយក្តាប់ទេ គ្នា១២នាក់ ដាំលាយជាមួយក្តួច តែយើងអត់ប្រឆាំងគេទេ ដឹងថាវាអត់ហើយ ។

កា : អត់ទាំងអស់?

ភីន : អឺ! អត់ទាំងអស់គ្នា ហូបហើយឡើងបេះដូងហូប ផ្លែដូងហូបបំពេញថែមទៅរស់ទល់សព្វថ្ងៃ អត់ប្រឆាំងទេ និយាយចឹងថាយើងមិនប្រឆាំងគេវារស់យូរ ។ ប្រឆាំងគេអត់រស់ទេ ជឿខ្ញុំទៅសង្គមមួយៗចឹង ។ ស្រាវជ្រាវបើថាកាត់ខ្មែរក្រហមកាត់ទាំងអស់ទៅ អានឹងខ្មែរក្រហម៨លាននាក់មនុស្សកាលនឹង ។ ឥឡូវឲ្យអាមេរិចឲ្យរាប់ឲ្យគ្រប់៨លានយកកាត់ទៅហើយយកគុកទៅដាក់ចុះ កាលនឹង៨លាន ។ អ៊ំចាំណាស់ មនុស្សខ្មែរយើងមានប៉ុននឹង ។ ហើយ៨លាន ងាប់អស់មួយលាន៥សែននោះ នៅសល់៦ដាងទេណាចប់សង្គ្រាម ។ ចឹងហើយបានគេខំបង្កើតមនុស្សការទាំងគូៗនឹង អាខ្ពស់យកទាប អាសយកខ្មៅនឹង ។

កា : ចឹងត្រូវបានប្តីស?

ភីន : អឺ! នាងឯងខ្មៅចឹង បានប្តីសកាលនឹង រត់អត់រួចទេ ។ ហើយមនុស្សខ្មែរយើងមានសមានខ្មៅចឹងឯង ពីដើមមិនមានសុទ្ធតែមនុស្សអាក្រក់ទេ ល្អដូចតែគ្នានឹង ។ ឥឡូវនេះបានលេបានអីជួយទៅ បានសបានអីចេះតែថាមួយៗសុទ្ធតែចិន ។

កា ៖ ខ្ញុំខ្មៅ ។

ភីន ៖ ហើយនាងឯងអត់លាបផង មិនខ្មៅ លាបដូចគេមើល ។

កា ៖ គ្មានលុយទិញលេលាបនឹងគេទេ ។

ភីន ៖ អឺ! វាចឹង វាក្រ យើងអត់ ។ ហើយគេអ្នកស ចេះថាគេចិនអី មិនទេ យើងខ្មែរដែរ ។ តាវ៉ៃៗ តានឹងចាមទេ ចេះមកធ្វើតស៊ូ ។

កា ៖ ពីសាលាស្រុកមក?

ភីន ៖ សាលាស្រុកគេឲ្យដើរសម្ភាសន៍តាមនឹង ។

កា ៖ មិនអីទេអីមិនបាច់សួរតាមនឹង អ៊ំឆ្លើយអស់ហើយ ខ្ញុំខ្ជិលសួរម៉ង(សើច) ។ ដឹងច្រើនជាង អានឹង មិនបាច់សួរតាមនឹងក៏ដឹង ។

ភីន ៖ នែក! អ្នកឯកសារ ឌី ខាំបូលី មនុស្សកើតក្រោយទេ ខ្ញុំអត់មានរៀនសញ្ញាប័ត្រអាមេរិច ឌី ខាំបូលី កើតនៅក្រចេះទេ ។

កា ៖ អ៊ំបានមើលសៀវភៅនឹងដែរ?

ភីន ៖ អឺ! ហើយគាត់ដឹងប្រវត្តិអីខ្មែរក្រហម បើនេះគ្មានទេពួកនេះ ធ្វើយកតែលុយចាយទេ ។

ប្រពន្ធ ៖ ដើរស្រាវជ្រាវ ។

ភីន ៖ ហ៊ើ! នាងនេះខ្ញុំមិនថាទេ ថាអ្នកឯងនោះ ។

ប្រពន្ធ ៖ ចឹង ឌី ខាំបូលី ដើរស្រាវជ្រាវតាមភូមិ ។

ភីន ៖ ស្រាវជ្រាវសរសេរកន្លែងខ្លះខុសទេវ ចេះតែសរសេរទៅ អាងគាត់ចេះសរសេរ ខ្ញុំអត់មានថាចេះតែថាទេ មនុស្សយុត្តិធម៌មានតែខ្មែរយើងនិងខ្មែរ តែមានបរទេសត្រួតពីក្រោយហើយ ចប់ហើយ យុត្តិធម៌រកមិនឃើញទេ ។ ឥឡូវនេះរកអត់ឃើញទេ តែនាងឯងកាប់ថ្មចំណាំផង ទៅដល់ផ្ទះកាប់មួយពុកឯង ។ ប៉ាឯងខ្ញុំកាប់ថ្មចំណាំ យុត្តិធម៌រកបាន អត់សាលាក្ដីនឹង ។

កា ៖ យូរហើយ?

ភីន ៖ អត់បានទេ គេប្រមូលតែលុយសម្រាប់ក្រុមគ្រួសារគេទេ ឥឡូវនាងឯងចំណាំមើលទៅ ឥឡូវប្រាប់ខែ ឌី ខាំបូលី ប៉ុន្មាន១ខែ នេះមិនស្រួលដល់ម៉ឺន ដល់ទេ?

កា ៖ អាច ។

ភីន ៖ ឌី ខាំបូលី នេះមិនមែនមនុស្សបរទេសទេ ខ្មែរយើងទេ ។ ខ្ញុំស្ដាប់ព័ត៌មានគាត់ក្ដីនឹង ខ្ញុំស្ដាប់រហូតអត់ដែលបានដេកលក់ស្រួលទេ ខ្ញុំស្ដាប់តែព័ត៌មាននឹង ។

កា ៖ អ៊ំគិតម៉េចដែរ?

ភីន ៖ អត់គិតម៉េចទេ ស្ដាប់គេមើលម៉ង់ គេធ្វើទៅវាល្អស្ដាប់ ឬមិនល្អតែប៉ុននឹងឯង ។

កា ៖ តែអ៊ំគិតថាល្អ ហើយក៏មិនល្អ?

ភីន ៖ កំពុងស្ដាប់អត់ទាន់ដឹងថាល្អ ឬមិនល្អផង ។

កា ៖ យូរហើយ?

ភីន ៖ អឺ! យូរ ។

កា ៖ អត់ទាន់ហើយមួយ ។

ភីន ៖ ដល់ស្ដាប់យូរទៅៗ គេធ្វើសម្រាប់យកលុយចិញ្ចឹមជីវិតកូនចៅគេ យកមនុស្សលក់យកលុយ ។

ប្រពន្ធ ៖ ចង់គេថាអ្នកស្លាប់នឹងយើងគិតម៉េចទេ?

ភីន ៖ ហ៎! អ្នកស្លាប់បងប្អូនអញក៏ងាប់ៗអស់ទាំងពូជដូចគ្នា អត់មានអ្នកណារស់ទេសម័យនឹង ងាប់ច្រើនណាស់ វេទនាណាស់ សម័យនោះ ។ ល្មមថាគេចោទថាមនុស្សងាប់មែន សង្គ្រាម៥ឆ្នាំ នាងអើយមានអ្នកណាមួយបាននៅផ្ទះ គ្មានផ្លូវរត់ចេះណា ងាប់ហើយយន្ដហោះអាមេរិចទម្លាក់ងាបផុតពូជអស់ ។ នាងឯងគ្រាន់តែដក់បារីហុយតែមួយស៊ុយឡើងលើ យន្ដហោះមកដល់មួយភ្លែតវាមានអីស្អីមើលលឿនម៉្លេះ ចឹងហើយដក់ថ្នាំក៏ក្ដោបចេះដែរ ទប់ទៅដីក៏មានដែរ ថ្នាំដក់យើងមិនបាច់ទៅស្អីទេ វាទំនើបដល់ប៉ុននឹងសម័យនោះ ទម្រាំសម័យនេះទៀត រិតតែទំនើបទៀត ។ អារឿងយើងមិនទាន់មាននឹង គេធ្វើបង្កើតឲ្យមានរូបហើយ ។ សម័យឥឡូវណា អ៊ីនធឺណេត ។ ខ្ញុំជឿមនុស្សខ្មែរយើងហើយខ្មែរ តែពួបរទេសនិយាយជាមួយហើយ ខ្ញុំលែងជឿ ពួកនេះមកក្រឡុកក្រឡាសម្លាប់តែខ្មែរយើង ចោលជឿខ្ញុំទៅ អាណាចេះសម្លាប់ហើយអត់មានទុកទេ ចោទថារឿងនេះរឿងនោះដើម្បីយើងសម្លាប់គេចោទយើងមុន ។ ធ្វើម៉េចធ្វើទៅ ហើយខ្ញុំស្ដាប់រាល់ថ្ងៃ វិទ្យុកញ្ចាស់១ពីរនាក់យាយ ។

កា ៖ ស្ដាប់បាន?

ភីន ៖ បាទ! តែស្ដាប់ព័ត៌មាននិយាយអីបាន បើថ្ងៃណាមិនភ្លៀងស្ដាប់បានទាំងអស់ បើថ្ងៃណាភ្លៀងបាត់អស់ហើយ លែងឮទៀត ។ ខ្មែរយើងអត់ឮទៀត ឮតែពេលព្រលប់នឹង ដល់យប់ជ្រៅលែងឮហើយ ប៉ុស្ដិ៍យើងស្ទឹងមានជ័យ ប៉ុស្ដិ៍វត្តភ្នំនឹង ទៅហើយបាត់ឈឹង ។ ទៅឮអាមេរិចណានៅឆ្ងាយៗ គេឮ ។

កា ៖ គេខ្លាំងជាងយើង?

ភីន ៖ អឺ! ប៉ុស្ដិ៍គេល្អជាងនឹងហើយតាមគិតទៅ ។

កា ៖ អានេះអ៊ីដាក់អីគេ?

ភីន ៖ ស្រលាង ដាក់យកភ្លៀងប្រើអាគុយ ប៉ុនអត់បានភ្លើង។

កា ៖ អានឹងអស់ប៉ុន្មាន?

ភីន ៖ ទិញគេ៣០០។

កា ៖ ហើយបានល្អទេ ប្រើ?

ភីន ៖ អត់ទេ គេបោកប្រាសម៉េចកាលនឹង លក់គោអស់មួយក្រាលបាន៣០០ ទិញអានឹងមួយ

កា ៖ ប្រើបានប៉ុន្មានឆ្នាំ?

ភីន ៖ គេថា២០ឆ្នាំ ប៉ុនទិញបាន៣ឆ្នាំ។

កា ៖ ចុះអត់ធានា?

ភីន ៖ គ្មានទេវា២០ឆ្នាំ វាថាធ្វើសំបុត្រធានារាប់រងឲ្យយើង ប៉ុនវាអត់ធ្វើផង ចឹងវាបោកប្រាស់យើង។

កា ៖ ចឹងមានគេស្តីទៅវា?

ភីន ៖ ហ៎! ប្រាប់លេខទូរស័ព្ទយើងមក គេស្តីទៅចូលអ្នកលក់ខោអាវណាតែផ្តាស់ អត់មានចូលវាទេ ខូចណាស់ ពួកនឹងនោះ។ ហ្នឹងហើយអត់មានមនុស្សប្រដៅមនុស្សទេឥឡូវនេះ នាងឯងប្រយ័ត្ន។

កា ៖ បោកៗប្រជាជនដល់នេះ បើមិនបានជួយជាតិក៏បោកប្រជាជន?

ភីន ៖ ឥឡូវខ្ញុំគ្រាន់ប្រដៅនាងឯង រៀនទៅល្អទៅ កុំបោកប្រាស់ដូចពួកគេចឹង មិនកើតទេ ហើយយើងទៅថាម៉េច ឲ្យប៉ូលីសចាប់វាចាប់បានមកគ្រាន់ឃើញមុខ ប៉ូលីសលែងទៅវិញបាត់ យើងអត់ពឹងគេកើតទេ។ មានតែយើងធ្វើល្អខ្លួនយើងតែប៉ុននឹងបានហើយ កុំឲ្យបាប អ្នកណាធ្វើអីធ្វើណាទៅ បាបរឿងគេរបស់គេ យើងកុំធ្វើអី មិនបាច់ទៅវត្តរាល់ថ្ងៃទេ នាងឯងធ្វើបុណ្យឲ្យនៅផ្ទះតាំងចិត្តឲ្យល្អទៅ ដូចថាសមាធិអីចឹង ល្អហើយ បានបុណ្យទៅឯងមិនបាច់យកបាយទៅវត្តខំស្ល សម្លឆ្ងាញ់ៗសាច់ជ្រូសយកឲ្យលោកអស់ អត់ឲ្យម៉ែឪហូបទៀតខ្លាចបាប អានឹងអត់ទេណា។ ឲ្យម៉ែឪយើងហូបឲ្យហើយចាំជួសឲ្យលោក អត់បាបទេលោកគេអត់ប្រកាន់ទេ។ គេថាព្រះកន្លោង ម៉ែឪយើងនេះហើយព្រះ គោរពគាត់។ កុំឡែងមួរម៉ៅ ដើរកាត់ក្តីកាត់ទោសណារឿងគេ ឯងយករឿងទៅគួបផ្សំផាប់ផុយណាស់ អត់យូរទេ។ ខួរក្បាលមនុស្សយើងមិនត្រូវការអីអារឿងពិបាកៗច្រើនទេ ត្រូវការរឿងសប្បាយច្រើនជាងពិបាក តែពិបាកច្រើនជាងអាយុខ្លី នាងឯងចំណាំមើល។ ទោះបីអ្នកធំក៏ដោយ អ្នកតូចក៏ដោយ ឲ្យតែមួរម៉ៅច្រើនពេកនឹង អត់រស់យូរទេ កុំធ្វើតែសប្បាយ

ម៉ាល្មម រស់ចូលនៅសង្គមគេចុះ កុំឲ្យទំនាស់ទាស់ទែងអីគេ គឺល្អល្មម ។ គេដឹកនាំគេសន្មត ថាគេត្រូវដែរ បានគេធ្វើដល់ធំៗចឹង បើកំណត់ថាគេខុស ក៏គេមិនដឹកនាំដែរ ។ ដូចឥឡូវ នេះសម្តេច ហ៊ុន សែន គាត់ធ្វើរហូតប៉ុន្មានឆ្នាំហើយ ។ គាត់ចាត់ទុកថាគាត់ធ្វើត្រូវបាន គាត់អត់ឈប់នោះ ។ ហើយយើងរស់នៅក្នុងរបបនឹង យ៉េងធ្វើឲ្យល្អដូចគាត់ចឹងទៅ ត្រូវ ជាមួយគេចឹងទៅ យើងដែរទៅណា ដែលណាគេសម្លាប់យើងធ្វើអី យកយើងដាក់គុកឲ្យ អាចម៍ស្អុយក្នុងគុកធ្វើអី អត់ទេ ។ ធ្វើម៉េចឲ្យតែត្រូវ កុំឲ្យខុស កូនខ្ញុំទៅក្រោយទៀត ខ្ញុំ ប្រដៅចឹង ឲ្យតែគេឡើងដឹកនាំ គេល្អកូនអើយគោរពគេចឹងទៅ ហើយតែប៉ុននឹង ។ បើកូន ឯងមិនគោរពគេ មិនធ្វើតាមគេប្រឆាំង ទៅហើយស្លាប់ហើយ គេធំជាងយើង គេសម្លាប់ យើងអ្នកតូច មនុស្ស អ្នកដឹកនាំធំគេសម្លាប់អ្នកតូច អាណាគេមិនគោរពបញ្ជាគេ ដែល មើលរឿងកុនចិន មិនបានទេ ។ មើលអានឹងញឹកគិច កុំមើលរឿងស្នេហា មិនបានការអី ទេ នាំតែខូចចិត្តនាងឯង ខំតែរៀនឲ្យធ្វើការបានធំៗជួយម៉ែជួយឪយើង ព្រោះយើងអ្នក ក្រ គ្មានមានទេ ។

ប្រពន្ធ : នៅបឹងកក់គេអត់ដេញទេ?

កា : ខ្ញុំនៅទួលសង្កែ បឹងកក់គេលុប ។

ភីន : ទួលសង្កែនឹងខុសកន្លែងដេញ ។

កា : ខុសកន្លែងដេញ ។ ភ័យដែរនឹងអ៊ី ខ្លាចគេដេញដែរ វាពិបាកដែរឥឡូវ តែគេចង់បានគេ ដេញ ។

ភីន : អឺ!អានឹងចឹងទេឯង ឃើញទេ ច្បាប់នៅលើមាត់ថាមិនមែនលើច្បាប់ ជឿអត់ ។

កា : ចា៎! ជឿ ។

ភីន : ជឿអឺអានឹងមួយ ។ ច្បាប់ទាំងអស់នៅលើមាត់ថាៗខុសៗ មាត់ថាខុសៗ មាត់ថាត្រូវៗ ។ ឥឡូវគេថាច្បាប់ចែងថា ធ្វើប្លង់រឹងឲ្យនាងឯង អានឹងថាច្បាប់ហើយ នាងឯងមានប្លង់រឹង ហើយប្រនៅ ។ យើងកំណត់ថាមានហើយចុះ ប្លង់រឹងគ្មានអ្នកណាទៅរើរុះបោកប្រាស់អីបាន ទេ ស្រាប់តែខាងលើត្រូវការ ប្លង់នឹងទន់ហើយអត់មានរឹងទេ ស្រេចមាត់គេថាទេ តែគេ ថាត្រូវៗ គេថាខុសៗ គេអ្នកធំជាងយើងនាងឯងប្រកាន់ប៉ុននឹងបាន ។ នាងឯងរៀនបាន ថ្នាក់ខ្ពស់ ធ្វើគ្រូវ៉ៃក្មេងក៏ចឹង អាក្មេងនឹងធ្វើត្រូវប៉ននាងឯងថា ហ៉េ!អានេះធ្វើខុសដាក់ក្លូស យំង៉ាចឹង ។ ដូចអ្នកដឹកនាំក៏ចឹង យើងធ្វើត្រូវសោះនឹង ប៉ុនគេថាខុស ដូចដីយើងមានប្លង់ ហើយគេមិនថាត្រូវ ស្រាប់តែគេមកដល់ថាអត់ទេ ដីនេះត្រូវគេយកធ្វើអីទៀតហើយ អត់ មានទេ ប្លង់នឹងក៏មិនបានការដែរ ចប់ប៉ុននឹង អសារបង់នៅនឹងមាត់គេថាមួយមាត់នឹង ។

កា : រឿងដងវាពិបាក ។

ភីន : ពេញប្រទេស ។

កា : ចឹងនៅនេះអត់មានដីណា?

ភីន : មានដែរនៅនេះ ប៉ុនតែវាស្ងាត់ណាស់ត្រង់នេះ អត់មានរញ៉េរញ៉ៃអីនឹងគេទេ ។

កា : ថ្ងៃមុននៅស្រុកឃើញមនុស្សមកមួយដុំ?

ភីន : នោះ ពាក់ព័ន្ធនឹងព្រៃស្អាក ។

កា : ព្រៃស្អាក?

ភីន : ព្រៃស្អាកនឹង ដែលគេយកធ្វើតំបន់អភិរក្ស ហើយវាប៉ះដីស្រែដីចំការរបស់គាត់ ។ គេវាស់មកដល់ជិតអន្លង់វែង ដល់ព្រលានយន្តហោះ ។ ប៉ុននាងឯងអត់ស្គាល់ព្រលានយន្តហោះ ។

កា : ព្រលានយន្តហោះនៅណា?

ភីន : នៅខាងកើតអន្លង់វែងតិច ប្រហែលមួយគីឡូកន្លះ ។

កា : ឥឡូវនៅសល់?

ភីន : វាស់មកដល់នឹង ប៉ុនដីអ្នកស្រុកគាត់ធ្វើហួសនឹងទៅទៀត ហើយវាស់មកយកដល់នឹងហើយ ។

កា : គេធ្វើរូបរាងដូចព្រលានយន្តហោះទេ?

ភីន : ព្រលានយន្តហោះសម័យដើម យើងកំណត់ចឹង ឥឡូវនេះគេគ្មានអ្នកណាធ្វើទេ ពីសម័យសម្ដេចសីហនុនឹងមានព្រលានយន្តហោះនឹងមួយ ។

កា : នៅសម័យកម្ពុជាប្រជាធិបតេយ្យអត់មាន?

ភីន : កម្ពុជាប្រជាធិបតេយ្យមានយន្តហោះណា មានតែពោធិ៍ចិនតុងនឹងមួយ ។ ដែលទៅមើលកំពង់ឆ្នាំងអត់ ។

កា : មាន ធ្លាប់ទៅមើល?

ភីន : អឺ! អានឹងហើយកម្ពុជាប្រជាធិបតេយ្យធ្វើ មួយស្រុកខ្មែរអត់មានទេ មានតែអានឹងមួយ ។

កា : តែឆ្ងល់ដែរ ប្រជាជនខំធ្វើនៅនឹងឡើងស្អាត ឥឡូវអត់មានធ្វើអីទុក ។

ភីន : គេយកធ្វើអីនាង អានឹង?

កា : ទុកចោល ខ្ញុំធ្លាប់ទៅមើលម្ដង ស្ដាយព្រោះរបស់ល្អ នៅឃើញល្អ ។

ភីន : ចំនាយរាប់រយលានដុល្លា ហើយបើសម្ដេច ហ៊ុន សែន គាត់ទុកធ្វើព្រលានយន្តហោះសម្រាប់ប្រទេសគឺល្អ ត្រង់នឹង ។

កា ៖ ចា៎! ឥឡូវខ្ញុំទៅមើលវាស្អាតមែន គេចាក់ឡើងស្មើ ។

ភីន ៖ ស៊ីម៉ង់នឹងម៉េចបែក នាងឯងទៅធ្វើអីបែក គេចាក់កំរាសកន្លះម៉ែត្រៗ បេតុងសុទ្ធម៉ង់ សម្រាប់យន្តហោះបេ៥២អត់ស្រុតទេ ប៉ុន្តែឥឡូវសម័យយើងឥឡូវនេះចុះអត់ទ្រុឌទេ ហើយ ១២គីឡូបណ្តោយ សម្រាប់ប៊ូអ៊ីងចុះ ។ ព្រលានស្រុកខ្មែរមាន សឹងថាស្រុកថៃមិនមានដូច ប៉ុនថា ខុសពីឥឡូវនេះខ្មែរយើងមិនប្រើ ចោលទៅ ។

កា ៖ ស្តាយណាស់របស់ដែលធ្វើ ។

ភីន ៖ អឺ! លុយសម្រាប់ខ្មែរ ប្រជាជនហូបបបរ តែយកលុយសល់នឹង ទៅធ្វើចិនៗសម្រាប់ ប្រទេស នាងឯងមើល ។ ខ្មែរយើងឥឡូវនេះមានរោងចក្រដេរខោអាវមកពីគេទៀត សម័យខ្មែរក្រហមមានរោងចក្រស្លដែក ឥឡូវមានរោងចក្រស្លដែកអត់នាងឯងដឹងនៅ ភ្នំពេញអ៊ំប្រាប់ មាន៧រោងចក្រស្លដែកនៅភ្នំពេញសុទ្ធ ។

កា ៖ ឥឡូវនឹង?

ភីន ៖ សម័យខ្មែរក្រហម៧រោងចក្រស្លដែក ប្រទេសរីកចំរើនទៅបានគេថាមានរោងចក្រស្លដែក បានរីកបាន បើមិនចឹងអត់ ។ យើងទិញគេទាំងអស់អត់រីកទេ ខ្មែរក្រហមមាន៧ ។

កា ៖ តែអ៊ំធ្លាប់ទៅដល់រោងចក្រនឹង?

ភីន ៖ ទៅមិនដល់ បើនៅភ្នំពេញដែរនឹង ។

កា ៖ អ៊ំនៅភ្នំពេញឆ្នាំណា?

ភីន ៖ អញបេះតែដើរនៅកាលនឹង គេមិនមានឃាត់អីដូចឥឡូវ ដីគេ ពីមុនមិនមានដីគេទេ ស្មើ ភាពគ្នាគ្មានអ្នកណាម្ចាស់ដីអត់មានទេ ។ រោងចក្រស្លដែក៧ ថ្មដែកនេះ ដឹកពីព្រះវិហារទៅ ស្លទៅបានដែកប្រើ ។ ហើយឥឡូវនេះដែកទិញគេទាំងអស់ ស៊ីម៉ងមានរោងចក្រស៊ីម៉ង់មួយ នៅចក្រីទីន, រោងចក្រស្លដែក៧ឃួនយកអស់, រោងចក្រប្រេងកាតមានអត់សម័យឥឡូវ, មានទេ?

កា ៖ អត់ទាន់មានទេ ។

ភីន ៖ អត់មានទេ សម័យខ្មែរក្រហមមានរោងចក្រប្រេងកាត នៅកំពង់សោម នៅកន្លែងរាល់ថ្ងៃ នេះ គេធ្វើហើយបានចំរាញ់ហើយ កាលនោះ អត់មានពឹងគេទេ ។ ចឹងវាខុសគ្នាចឹង ។

កា ៖ ចឹងកាលនោះអ៊ំដើរបានច្រើនដែរ?

ភីន ៖ អឺ! អញដើរមើល យើងនៅតាមសហករណ៍ អាណារៀងអន់ៗដាងគេៗដឹកដើរលេងចឹង ណា ។ គេដើរទស្សនៈកិច្ចចឹង ដូចឥឡូវចឹង អាណាមានលុយគេទៅៗឥឡូវនេះណា ។ ពី មុនអត់ទេ ដល់គេឲ្យទៅយើងបានទៅ គេមិនឲ្យទៅអត់ទៅ ។

កា ៖ មានឡានមានអីជិះដែរ?

ភីន ៖ យ៉េ! សុទ្ធតែឡានអ៊ី កុំបេះតែថា សម័យខ្មែរក្រហមអត់ឡានណា នោះទៅមើលស្រុកយួន នោះឡានខ្មែរក្រហមនៅនឹងទាំងអស់រាប់ពាន់ម៉ឺនគ្រឿង ។

កា ៖ តែកាលនឹងអត់មានប្រទេសណាឈ្លានពានបានទេ?

ភីន ៖ មិនមានទេ នាង ។

កា ៖ ដូចនៅនេះការពារបានល្អ ។

ភីន ៖ ឥឡូវអញចង់ប្រាប់តិច ប៉ុនមិនចង់ប្រាប់គេមិនសួរ ។

កា ៖ ប្រាប់មកអ៊ំ បើខ្ញុំមិនដឹងថាខ្ញុំត្រូវសួរអី បើអ៊ំឯងដឹងច្រើនប្រាប់មកឲ្យខ្ញុំដឹងផង ។

ភីន ៖ ការពារបាននាងអើយ ដូចអ៊ំនិយាយមិញចឹង ថាគេចំនាយកម្លាំងមនុស្សណាស់បានៗ បើមិនចឹងទេ អត់បានទេ ។ ហើយខ្មែរក្រហមនេះ អត់មានពឹងអ្នកណាទេ មនុស្សតិចមួយ ហើយអត់ពឹងគេទេ ។ ពឹងតែទិញៗពឹង ព្រោះយើងអត់មាន ទិញចិន ខ្ញុំប្រាប់ចឹងម៉ង់ទៅ ។

កា ៖ ទិញអីទៅ?

ភីន ៖ ទិញរបស់របរប្រើចឹងទៅ គេលក់ឲ្យយើង ទិញតែចិននឹងឯង មនុស្សគឺយើងខ្លួនយើង ប្រើខ្លួនយើង យួនវ៉ៃខ្មែរយើងតាំងពី៧៦ អ៊ំប្រាប់ឆ្នាំ៧៦ អ៊ំប្រាប់ ។ ឆ្នាំ៧៦ គ្រាន់រំដោះហើយភ្លាម រំដោះពីអាមេរិចកាំងវ៉ៃហើយភ្លាម យួនវ៉ៃទៀត ។ របេះរបោះតាមព្រំដែនរហូតមក ។ វ៉ៃ២ឆ្នាំ វ៉ៃជាមួយខ្មែរយើងវ៉ៃអត់ឈ្នះ ខ្ញុំប្រាប់វ៉ៃខ្មែរយើងអត់បានទេ ។ តែដល់ទៅវ៉ៃមិនបានរត់ទៅពឹងអឺរ៉ុបខាងកើត សូវៀត គុយបា ១៨ប្រទេសមកបានជួយវ៉ៃខ្មែរបានៗ បានខ្មែរក្រហមមកនៅព្រំដែន កុំអីអត់ទេ បើថាតែយួនសុទ្ធស្រេចហើយយួន ។ អ្នកឯងកុំថាយួនខ្លាំងនោះ អត់ខ្លាំងទេ ខ្ញុំអត់ជឿទេ អ្នកណាថាខ្លាំងអត់សោះ យួនរត់ទៅពឹងគេដែរ កុំពឹងគេអត់វ៉ៃឈ្នះខ្មែរទេ ពួកឈ្លានពាន ។

កា ៖ ចឹងអ៊ំឡើងមកលើភ្នំពីឆ្នាំណាទៅ?

ភីន ៖ មកលើភ្នំនេះមកតាំងពីនេះនោះ ឆ្នាំ៨១ ខ្ញុំមក៨១ ។

កា ៖ កាលនោះពិការហើយ ។

ភីន ៖ ពិការហើយ យើងមករួចហើយសល់ពីគេបាញ់ ។

កា ៖ រត់ពីយួន?

ភីន ៖ អឺ! ផាប់អត់អស់ សល់ខ្លះ ។

កា ៖ ត្រូវកន្លែងណាខ្លះ សុំមើលតិច?

ភីន ៖ នេះសុំមើល អញឲ្យថតទៀត ។

កា ៖ តែដើរអី ដើរកើត?

ភីន ៖ ដើរនៅដើរកើត តែយើងដើរខ្យល់ៗ ។

កា ៖ កន្លែងនេះត្រូវដែរ?

ភីន ៖ នេះកន្លែងនេះទាំងអស់ត្រូវកន្លែងនេះដែលត្រូវ ។

កា ៖ ប៉ុន្តែវះ?

ភីន ៖ វះយកឆ្អឹង វាបែកឆ្អឹងអស់រលីង វាដាច់សរសៃរខួរនេះមកខូចម្រាមអស់ ហើយអានេះវាដាច់សរសៃរនេះ ។

កា ៖ តែឈឺទេ ពេលយប់ឡើង?

ភីន ៖ ឈឺរហូត ពីនោះមកដល់នេះឈឺរហូត ព្រោះវាបែកឆ្អឹងៗស្តោត អត់បេះជាទេ ។

កា ៖ មេឃត្រជាក់អីនៅឈឺទេ?

ភីន ៖ ឈឺ ទាល់តែយើងលេបថ្នាំរហូតពីនោះមកឥឡូវលេបថ្នាំជាប់ចឹង ទិញថ្នាំលេបការពារហើយមើលពាក់ទ្រនាប់ជេងអាក្រក់បំផុត វាពាក់ក្រៅពីនឹងពាក់អត់ជាប់ យើងពាក់អានេះអត់មានអីក្រវ៉ាត់ពីក្រោយអត់ជាប់ទេ ដែលវាខូចអស់ហើយ ។ យ៉ាប់ណាស់ កុំឲ្យពិការធ្វើសង្គ្រាមបើថាងាប់ៗផុតទៅ កុំឲ្យពិបាក ។ ពិការពិបាកណាស់ ពិបាកយូររហូតដល់ស្លាប់ទៅវិញ នេះពិការប៉ុននេះ ។ ចុះអាកំបុតស្មុទ្ធម៉ង់ រិតតែពិការយ៉ាប់ទៀត អត់ស្រួលទេ ធ្វើម៉េចកុំឲ្យកើតសង្គ្រាម យ៉ាប់ចឹង ។ តែកើត ពិការហើយងាប់ ។

កា ៖ ដូចសង្គ្រាមថៃ ជាមួយខ្មែរយើង?

ភីន ៖ អឺ! សង្គ្រាមនៅថៃ នាងឯងកាលសង្គ្រាមនេះ ដែលមកអើតទេ កាលមុន ។

កា ៖ ខ្ញុំមកមុន នៅព្រះវិហារ ។

ភីន ៖ មានតែប្រជាជនរស់នៅនេះ ទាហានគេនៅលើ អត់រត់ទេ នៅនេះមិនរត់ទេ ។

កា ៖ បាញ់ត្រូវទេម៉្លឹង?

ភីន ៖ អឺ!

កា ៖ បាញ់ដល់?

ភីន ៖ បាញ់ នេះបើបាញ់ហួស ចុះនៅជិតនេះបង្កើយ បាញ់មកបន្តក់ហួសទៅនោះ ប៉ុនកន្លែងនេះវាអត់ផ្ទុះ បាញ់ទៅលិចប្រាសាទតាមាន់ ។ ប៉ុនយើងរត់ទៅភ្នំពេញ មានដីណានៅ បើនាងឯងមានដីទួលសង្កែតិចនឹង ប៉ុន្មានម៉ែត្រមាន ឥឡូវនេះ ។

កា ៖ តិចគួចនង់ តែផ្ទុះមួយ ។

ភីន ៖ ២០ម៉ែត្រទេ ។

កា : អូ! គ្មានដីណាដល់២០ម៉ែត្រនៅ ។

ភីន : អត់ដល់ទេ ។

កា : អត់ទេ នៅភ្នំពេញវាចង្អៀតៗ មានដីណាទូលាយដូចនៅនេះ ។

ភីន : បាន១៥?

កា : ផ្ទះខ្ញុំតូចនឹង មិនបានផ្លូវចូលមកផ្ទះអ៊ំផង?

ភីន : អានឹងស្រុកគេធ្វើដីឡូតិ៍ចឹងឯង ប៉ុនបានវែងទេ?

កា : ដូចបាន១០ម៉ែត្រ ។

ភីន : អឺ! នៅទួលសង្កែយូរហើយ អត់ព្រមយកឲ្យធំ សុទ្ធតែបឹងទេ ពីមុនគ្មានដីណា ។

កា : មនុស្សកាលពីមុនក៏មិនគិតថា វានៅនេះច្រើន មិនបានសង្ឃាតអីគិតតែ កុំឲ្យមានសង្គ្រាមទៀត ប៉ាខ្ញុំនិយាយចឹង ។

ភីន : កុំឲ្យមានកើតទៀត ។ ដែលពុកប៉ានិយាយនៅណាសម័យនោះ?

កា : ប៉ាខ្ញុំនៅបាត់ដំបង ។ មនុស្សបាត់ដំបង មនុស្សធំៗ មនុស្សអត់ល្អិតទេ ។

ភីន : ធំម៉េច?

កា : ធំ មាឌធំ អីនឹង មនុស្សអត់ល្អិតទេ បាត់ដំបង ។ ដីងច្រើនមែនទែនថ្ងៃនេះ ចែករំលែកឲ្យក្មេងជំនាន់ក្រោយ ។

ភីន : ឲ្យក្មេងដឹង កូនខ្ញុំក៏និយាយប្រាប់ដែរ ខ្ញុំនិយាយខ្ញុំអត់មានឯកសារអីនឹងគេទេ ប្រៀនប្រដៅកូនខ្លួនឯង យើងគ្មានសិទ្ធិប្រដៅគេ ប្រដៅកូនខ្លួនឯង ។ នាងឯងត្រូវចាំចងឯងប្រវត្តិសាស្ត្រខ្មែរយើង មិនដែលអ្នកណាសម្លាប់អ្នកអន់ទេ សម្លាប់អ្នកចេះនេះឯង ។

កា : ចា៎! ពិបាកត្រង់ថា ប្រវត្តិសាស្ត្រយើងរៀន មានតែបរទេសអ្នកចារ ។

ភីន : អឺ! នាងឯងត្រូវយល់ទៅ ចឹងឯង ហើយដែលបរទេសណាចារឥឡូវខ្ញុំប្រាប់ ខ្ញុំសួរនាងឯងទៀត ប្រទេសណាដែលយុត្តិធម៌អត់ឈ្លានពានស្រុកយើង អានឹងនាងឯងចាំជឿ បើប្រទេសឈ្លានពានស្រុកខ្មែរ ហើយចារឲ្យយើងរៀនកុំជឿ ។ រឿងបារាំង ខ្ញុំប្រាប់ឲ្យនាងឯងដឹង ប្រវត្តិសាស្ត្រឲ្យដីកម្ពុជាក្រោមទៅយួន ឆ្នាំប៉ុន្មាន៤៩នេះទេ ឆាប់ៗនេះទេ ឥតយូរទេ ។ ហើយឥឡូវបារាំងធ្វើម្ចាស់អីណាកន្លែងសាលាក្តីកាត់ទោស កាត់អីណា បារាំងក៏មកដែរ គេអ្នកឲ្យលុយ ខ្ញុំអត់ជឿទេ ពួកយកដីខ្មែរឲ្យគេ ពួកសម្លាប់ខ្មែរនេះ ខ្ញុំអត់ជឿទាំងអស់ ។ ខ្ញុំជឿតែខ្មែរ ដូចសម្តេច ហ៊ុន សែន ដូចអីខ្ញុំជឿ ឲ្យតែខ្មែរ ប៉ុនពួកនោះមកបញ្ឆោលែងជឿលែងអីខ្ញុំជឿវា នាំបាបទេ ។ អាពួកមកសម្លាប់អស់រលីងពេញប្រទេសមកចោទគេអាក្រក់ទៀត គេម្ចាស់ប្រទេស ។ នាងឯងគិតមើល អាមេរិចប្រវត្តិសាស្ត្រ

គាត់នៅស្រុកខ្មែរ ខ្វះស្អី ហើយមកចោទថាខ្មែរក្រហម អីតែខ្លួនគាត់នឹង ។ មានតែខ្មែរទេ ដែលចោទថាខ្មែរអាក្រក់ល្អបាន គេដឹងគ្នាគេ ។ បើសម្ដេច ហ៊ុន សែន ឲ្យគាត់តែ៣ចាស់នឹង គេអត់ព្រមទៀត គេថាទៅកាត់អានោះទៀតកាត់ដល់សហករណ៍ទៀត ។ អាចឹងមិនហៅឪវាមកកាត់ផងទៅ ឪអាមេរិកកាំងមកទម្លាក់គ្រាប់បែកនៅនេះ ជំនាន់អាឆនីខាតទ័រ ហើយជំនាន់អាស្អីនោះ ។

កា : ដល់ពេលគេនាំដើរដិះឡានអីដើរគ្រប់ខេត្ត? កាលនឹងអីពិការនៅ?

ភីន : ពិការហើយ អឺធ្វើអីលែងកើត ។ កាលនឹងគេមានរបបទស្សនកិច្ច ដោយអត់លុយ ចុះកាលនឹងអត់ចាយលុយដែរ ដូចនាង៦ងឥឡូវនេះ ឲ្យនាង៦ងមកទស្សនកិច្ចគេចេញលុយចេញអីឲ្យចឹង ។ ប៉ុនសម័យនោះ អត់មានលុយទេ តែយើងទៅគេហៅទៅអីចឹង គេឲ្យបាយយើងហូបទទេរ ហើយគេឲ្យផ្ទះយើងដេករៀបរយអី ដូចឥឡូវចឹងប៉ុនគ្រាន់អត់ចាយលុយ ខុសគ្នាតែប៉ុននឹង ។ ទៅលេងទៅអី កំពង់សោម មាត់សមុទ្រ សប្បាយៗ ទៅដេកសណ្ឋានចឹង សណ្ឋានគាត៧ជាន់នាង៦ងស្គាល់ទេ ។ ដែលទៅនៅ?

កា : នៅកំពង់សោម តែអត់ដែលសណ្ឋាគារនឹង ។

ភីន : អត់ស្គាល់ អា៧ជាន់នឹង នៅជិតកោះពស់ ជិតផែ សណ្ឋាគារមានមួយកាលនោះ សម័យនោះ៧ជាន់ជណ្ដើរយន្ត កំពស់វាទាបទេ ប៉ុនវាដាក់ជណ្ដើរយន្ត ។ ប៉ុនឥឡូវនេះគេកែថាដាក់ប៉ុន្មានជាន់ ខ្ញុំឮ ខ្ញុំសួរគេ គេធ្វើតខ្ពស់ ។

កា : អឺដែលបានទៅលេងភ្នំពេញ?

ភីន : ឥឡូវនេះ អត់ទេ នាងអើយ អាស្រុកកំណើតអត់ដែលបានទៅលេងទៀត យើងអត់មានសោហ៊ុយណានៅតាកែវ លោកអើយទៅមក២០-៣០ម៉ឺន វាអត់មានលុយឲ្យបងប្អូនទៀត ចប់ ។

កា : ខ្ញុំជិះទៅភ្នំពេញទៅមកអស់ ។

ភីន : អស់ប៉ុន្មានម៉ឺន?

កា : ជិត១០ម៉ឺន ។

ភីន : ជិត១០ម៉ឺនទៅមក?

កា : ចា៎!

ភីន : ឃើញទេ ទម្រាំយើងទៅនោះទៀត ។ ទៅទៀត ៧០-៨០គីឡូដល់តាកែវ ហើយផ្ទះខ្ញុំហួសទៀត ចង់១០០ដែរនឹង ។ ខ្ញុំទៅម្ដងកាលយើងសមាហរណកម្មនេះ ទៅលេងស្រុកម្ដង ទៅជួបបងប្អូននៅទាំងអស់ ប៉ុនចាស់ៗអស់ហើយ ។ ខ្ញុំពោគេ ហើយខ្ញុំ៦០ទៅហើយ

ចុះទម្រាំបង ៨០-៩០ហើយ ។ ប៉ុនបងប្អូនខ្ញុំកាលនឹងអត់មានគ្រោះថ្នាក់អីទេ កាលសម័យសង្គ្រាមនឹង ពិការតែខ្ញុំមួយទេ តែបងប្អូនដីដូនមួយ ។

កា : តែនៅបែកគ្នា?

ភីន : នៅបែកគ្នាៗដូចខ្ញុំថាមិនខុសទេ ឲ្យតែយើងធ្វើល្អពីសម័យ តឹងតែងម៉េចក៏អត់ងាប់ដែរមនុស្ស បើគេដឹងសម័យគេតឹងហើយ ឯងធ្វើប្រឡោចអត់គោរពគេ អត់អីគេទៅហើយមិននៅទេ ហើយអាងមកចោទគេថាដល់ពេលគេចេះ តែការសម្លាប់មែនហើយ ការស្លាប់មែន តែបើយើងគិតពីកំហុសយើងពីនោះទៅមានដូចគ្នា ។ រឿងដូចអ្នកកាសែតអីងាប់ភ្នំពេញអី មុនៗ អានឹងវាចឹងហើយងាប់ ជជេស តែគេថាកុំទៅយកព័ត៌មានអាកន្លែងនឹងវាខុសទេ កុំទៅនិយាយទៅផ្សាយ នៅតែទទូចក្បាលសំរុកចូល ត្រូវគ្រាប់កាំភ្លើងផូស នេះឥឡូវក៏គេបាញ់ ឃើញទេ គ្មានអ្នកណាគេវៃ អត់ទេគេបាញ់ម៉ង កាំភ្លើងសំបូរណាស់ ។ ចឹងឯង អាធ្វើម៉េចធ្វើតាមគេអត់ចេះងាប់ទេ ។ ប៉ុនរឿងអីដែលគេធ្វើចឹង គេប្រឆាំងគ្នានឹងឯង ដឹងទេស្រុកខ្មែរយើង នៅប្រឆាំង ។ មានអ្នកពីក្រៅមកប្រឆាំងជាមួយយើងអ្នកក្នុងស្រុកនឹងចឹងទៅ គ្មានអ្នកណាធំជាងអាមេរិចនេះទេ ខ្ញុំប្រាប់ ខ្មែរយើងធ្វើល្អមែននៅអាមេរិចថាខុសដែរ ធ្វើតាមគាត់ទៅបានត្រូវ ខ្មែរយើងមិនសូវធ្វើតាមគេ ។ សម្តេច ហ៊ុន សែន ក៏មិនសូវធ្វើតាម ។ ដល់គាត់មិនធ្វើតាម ថាគាត់ខុស ចឹងឯងដូច្នេះចេះតែរង្គោះរង្គើលឈ្លោះទាស់ៗ មិនចេះឈប់ទេ ។ នាងអើយចេះបានមកសួរ អ៊ំមិននិយាយ បានសួរអ៊ំហ៊ាននិយាយ ។ ដូចលើកមុនមក គេមកធ្វើវេទិការនៅវត្តនេះ ហើយក្មេងៗដូចនាងឯង ប៉ុនមកមុនប្រុសទេ ចាស់ម្នាក់ ។

កា : វេទិការអីគេ?

ភីន : ដែលគេសួររឿងកាត់ទោសដែរនឹង កាត់ទោសខ្មែរក្រហមយើងមានអារម្មណ៍មានអីរបៀបដូចថាសំនួរដូចគ្នានឹង ។

កា : វត្តស្រះឈូក ។

ភីន : វត្តស្រះឈូក សំនួរនេះ អត់មានសួរដល់ចឹង ខ្ញុំក៏អត់និយាយដែរ ខ្ញុំឌិល គេសួររឿងស្អីទេកាលនឹង កាលរឿងអីដែលខ្មែរក្រហមសម្លាប់មនុស្សសម្លាប់អីចឹង ហើយសហប្រជាជាតិគេស្រែកគេអ៎ ខ្ញុំសួរគាត់តើ ។ ហើយឥឡូវនេះ នាងឯងខ្ញុំសួរមើលឆ្លើយបានអត់ ។

កា : សួរម៉េចអ៊ំ?

ភីន : ហើយនាងឯងដឹងអត់ ពេលដែលគេថាខ្មែរក្រហមសម្លាប់ប្រជាជនខ្មែរ ។

កា : ខ្ញុំកើតអត់ទាន់ ។

ភីន : អង្គការសហប្រជាជាតិនៅគាំទ្រខ្មែរក្រហមពេញទំហឹង ។

កា : អានឹងដឹង ថាកាលនឹងខ្មែរក្រហមយើងមានអសនៈនៅអង្គការសហប្រជាជាតិ ។

ភីន : នៅអង្គការសហប្រជាជាតិណា៎ ។

កា : ទៅប្រជុំធម្មតា?

ភីន : អឺ! ទៅប្រជុំធម្មតា គ្មានបាត់មុខទេណា ហើយម៉េចក៏ចោទថាខ្មែរក្រហមសម្លាប់មនុស្ស អង្គការសហប្រជាជាតិមិនស្រែក ហើយគាត់នៅពេញស្រុកខ្មែរ គេអត់បិទទេ មកពេញ ។ ហើយម៉េចក៏ស្រែកថាខ្មែរក្រហមសម្លាប់ បើប្រជាជនខ្មែរពិបាកម្លឹងៗ ហើយទាល់មកឥឡូវនេះ សហប្រជាជាតិម៉េចក៏ស្រែកថាខ្មែរក្រហមសម្លាប់មនុស្ស ។

កា : បើកាលនឹងដឹងថាសម្លាប់ ហេតុអីមិនដកកៅអី?

ភីន : អឺ! ប្រជុំរហូតដល់៧៩ ដល់មកឥឡូវនេះ ក្រុងប៉ារីសក៏មានខ្មែរក្រហមចូលរួម ក៏មានខ្មែរក្រហមដែរ រឿងអីដែលគេគាំទ្រគេខ្មែរក្រហម ។ ចង់ស្ដាប់ទេ?

កា : ចង់ ។

ភីន : ចង់និយាយតិចទៅ គានអ្នកណាទប់យួនទេ មួយប៉ែកខាងនេះ អត់មានទេ គេយកខ្មែរក្រហមទប់យួនឲ្យថៃដឹងនៅ ។

កា : ទប់យួនវ៉ៃថៃម៉េច?

ភីន : យួនវ៉ៃខ្មែរហើយ យួនទៅវ៉ៃថៃទៀត គេឲ្យខ្មែរក្រហមអ្នកទប់ កម្លាំងគេពីក្រៅគេអត់ទេ គេជួយតែច្បាប់ទេ ផ្លូវច្បាប់ សហប្រជាជាតិក៏ជួយថៃក៏ជួយខ្មែរក្រហមដែរ អាមេរិចកាំងក៏ជួយខ្មែរក្រហមដែរ ។ នាងឯងអត់ដឹង ខ្ញុំប្រាប់ឲ្យដឹងទៅចុះ ។ ដូច្នេះខ្មែរក្រហមទប់យួនបាន អត់ទៅវ៉ៃថៃបានទេណា អត់វ៉ៃបានទេ ទប់ត្រឹមស្រុកខ្មែរនឹង ។ ដល់ពេលខ្មែរក្រហមសំរុះសម្រួលគ្នាជាមួយរដ្ឋាភិបាល ខ្មែរនិងខ្មែរឈប់វ៉ៃគ្នា ចាប់ផ្ដើមចោទខ្មែរក្រហមថាខ្មែរក្រហមសម្លាប់មនុស្ស សហប្រជាជាតិក៏បែរទៅមុខប្រាវទាំងអស់គ្នា ឈប់ហើយ ផ្ដាច់ពីខ្មែរក្រហមហើយ ។ ស្រែកថា ខ្មែរក្រហមអាក្រក់កាលនឹង ឥឡូវនេះ ពីមុនអត់ទេខ្មែរក្រហមល្អខ្លាំងណាស់នាងអើយ កៅអីក្នុងអង្គការសហប្រជាជាតិ៥ឆ្នាំ ៦ឆ្នាំ អត់មានធ្លាក់ទេ គាំទ្រ១៥០ប្រទេសនោះ បោះឆ្នោតគាំទ្រខ្មែរក្រហមនោះ ។ ចុះម៉េចឥឡូវនេះស្រែកថាខ្មែរក្រហមអាក្រក់ កាត់ទោស ។ មនុស្សនេះខ្លាំង ខ្ញុំប្រាប់នាងឯង ប្រទេសជិតខាងឈ្លានពានដីមិនបានទេ អាមនុស្សចាស់ៗ២-៣នាក់ក្នុងគុកនោះ ។ ឲ្យតែពុថារឿងដីគឺក្ដៅក្រហាយណាស អត់មានដូចយើងឥឡូវ ពីមុនមកឥឡូវនេះទេ ។ ថាយកដីបានមួយចំអាម ហើយប្រាសាទព្រះវិហារកាលនឹងខ្មែរក្រហមនៅតែ២នាក់ម៉េចមិនមកវ៉ៃយកទៅ ។ ខ្មែរ

ក្រហមមិនមានមនុស្សដងនឹង  ហើយម៉េចទើបមកវ៉ៃយកឥឡូវនេះ ។  នាងឯងពិចារណាមើល ។

កា :   ឥឡូវខ្លាំង?

ភីន :   រឿងអាពួកងាប់យកនេះចឹងឯង នាងអើយអាខ្មែរក្រហម ។

កា :   ប៉ុន្តែទាហានខ្មែរក្រហមនេះឡើងទៅប្រាសាទព្រះវិហារតើឥឡូវនេះ ។

ភីន :   កុំបានអារេរាំងនៅនឹងថៃយកបាត់ហើយ ។

កា :   ប៉ាខ្ញុំថាចេះ  អើយ  ពួកថៃនេះមិនឈ្នះទាហានខ្មែរក្រហមទេ  បាថាឃើញតែស្មៀកក្រមាមួយចងក្រវ៉ាត់ចង្កេះទៅហើយ ។

ភីន :   នាងឯងឃើញគេស្ពាយសាក់កាដូហើយក្រវ៉ាត់ចង្កេះក្រមា  ក្រវ៉ាត់ទ្រនាប់ជើង  អត់ពាក់ទេហើយរឿងអីអានឹង ។

កា :   ប៉ាថាមិនឈ្នះខ្មែរក្រហមទេ ។

ភីន :   អាមេរិច  នាងឯងដែលឮអាមេរិចស្រែក  ថាខ្មែរនេះ  សម្តេច  ហ៊ុន  សែន  អត់ទិញទ្រនាប់ជើងឲ្យទាហានពាក់ ។  សម្តេច  ហ៊ុន  សែន  គាត់ឆ្លើយទៅវិញថា  ខ្មែរក្រហមគេពាក់តែអានឹងទេ  ស្រណុកឡើងភ្នំ  ស្រណុករត់  គេអត់ដែលពាក់អាខ្ជប់នោះរត់មិនរួចទេនោះ ។  បើកឲ្យគេក៏គេមិនយកដែរ ។  អត់ពាក់ទេ  វាមកដើរលេងនៅក្រៅៗចេះពាក់  បើទៅច្បាំងលែងពាក់ហើយ  ទ្រនាប់ជើងផ្ទាត់ពាក់អានឹង ។

កា :   ប៉ាខ្ញុំឈ្នះ  គាត់ថាឃើញទាហានខ្មែរចឹងមែន  ប៉ុន្តែសុទ្ធតែយុត្តិសាស្រ្តពេញខ្លួន  ហើយទីតាំងអីល្អ ។

ភីន :   សំខាន់មនុស្សយើងកុំតែខ្លាចទៅបានហើយ    ឈ្នះគេហើយ    បើថាឮកាំភ្លើងរត់ផ្តាំម្តាយយកចេញទៅៗច្បាំងនៅណាមិនបានទេ ។  គ្រាប់កាំភ្លើងវាមានចេះត្រូវណាមួយគ្រាប់វាមិនមានទេ   បាញ់ឡើងព្រឹកថ្ងៃត្រង់មិនត្រូវម្នាក់ក៏មានដែរ ។   ហើយឯងមិនដឹងឮគ្រាន់ឮផ្ទោងក្តិលរត់ផ្តាំម្តាយបាក់កបាក់ស្រោកទៅធ្វើអី ។  ឥឡូវនឹងនាងឯងមើល  កាំភ្លើងរាប់ពាន់ដើមនៅលើនេះ   គេតំរង់កាណុងមក   ហើយម៉េច   ប្រជាជនម្តុំនេះមិនរត់ទៅបាត់ទៅ ។  នោះអន្លង់វែងរត់មកអស់រលីងផ្សារ  ទៅរលីងចេះអស់  ភ្នំពេញ  ផ្ទះគេនៅកំពង់ចាម  កំពង់ស្ពឺណាក៏ចេះតែទៅ  បានពួកនេះមកពីនិរតីទៅរត់ទៅណា ។  ហើយអាថៃវាឃើញចឹង  ថាយើងទម្រន់អីអីថាពួកនេះវាខ្លាំង   ការពិតផ្ទះនៅនេះហើយទៅណា   ឲ្យតែកាំភ្លើងមកបាញ់ទៀតហើយ   អត់ទៅទេ ។  ខ្ញុំអត់មានទឹកឃើញថា  នាងឯងមកសួរភ័យចេះចុះ  ខ្ញុំចង់ប្រាប់នាងឯងឲ្យដឹងផង  ក្មេងក្រោយអត់ដឹងទេ ។

កា : មិនប្រាប់ម៉េចដឹង បើដឹងតែរឿងគេផ្សេងទេ ទាល់តែសួរប្រជាជនទើបដឹង ។

ភីន : សាលារៀនខ្ញុំយល់ហើយ រឿងផ្សេងហើយ តែរឿងពិតមិនដឹងទេ សាលារៀន អាខ្លះមកដល់ដេរអា ប៉ុល ពត ។ ខ្ញុំសួរក្មួយឯងស្គាល់អត់នឹង? ទេ!ខ្ញុំអត់ស្គាល់ទេ ។ ខ្ញុំថាបើមិនស្គាល់ដេរធ្វើអី នាំបាបយើងទេ ដេរគេធ្វើអី ។

កា : ចុះដែលគេនាំអ៊ីទៅមើលសាលាក្តីនឹងអត់ភូមនឹង?

ភីន : ភូមិនឹងគេនាំតើ ប៉ុនគេចាត់មនុស្សទៅម្តងម្នាក់ ។

កា : ចុះអ៊ីបានទៅទេ?

ភីន : អត់ទេ ខ្ញុំមិនទាន់បានទៅទេ ទៅគេបានទៅហើយ ។

កា : អ្នកដែលបានទៅដូចអ៊ីរឿងនឹង គាត់អត់សប្បាយចិត្តសោះ?

ភីន : អឺ! ពួកណាទេបានទៅ អារឿងបានទៅ ទៅណាសន្យាគ្នាឲ្យបាយគ្នាហូបទៅ អត់បាយស្មោះ កុំបានដាក់លុយផ្ទះទៅនាប់នៅភ្នំពេញនឹងឯង លើកក្រោយកុំបបួលអត់ទៅទេនោះ ។ ដែលនៅជាមួយខ្ញុំនៅភូមិនេះ គេយក២១នាក់ ទាល់តែទៅខ្លះគេថាសាលាក្តីឲ្យបាយហូបហើយ ឲ្យផ្ទះដេកទៀត ។ ខ្ញុំចេះជួយថានែក!វើយ ដាក់លុយដាក់អីខ្លួនឯងខ្លះការពារកុំឲ្យអត់ បើគេឲ្យហូបយើងអរហើយ តែគេមិនមែនមិនឲ្យទេ គេឲ្យនំបង់មួយៗ ហ៉ើយអត់បានដេកបានអីទេ នៅតែលើឡានធក់សំកុកនៅនឹងទៅ ។

កា : ដល់ពេលចឹងអ៊ីលែងចង់ទៅ?

ភីន : អឺ!អត់ទៅទេ ខ្ញុំពិបាកដើរផង គេឲ្យទៅក៏មិនទៅដែរ ខ្ជិល អៀនគេទៅដល់នឹងឯងដើរបាក់ពើកទៅមើលណាអាខ្មែរគ្នាឯងជាប់គុក ធ្វើដូចបាក់មុខខ្លាំងណាស់ ។ ខ្មែរគ្នាឯងដាក់គុកឯងនាំគ្នាទៅមើលដូចជ្រូកក្នុងទ្រុង ។ ហ្នឹងហើយដូចទៅតថ្លៃជ្រូកទិញ ខ្មែរគ្នាឯងសោះ បើថាទៅមើលយួន ទៅមើលអាមេរិចណានោះទំនងមនុស្សមិនដែលស្គាល់ ហើយទៅនាំខ្មែរទៅមើលខ្មែរជាប់គុក មិនខុសគ្នាសម័យអាចារ្យស្វា ពោធិ៍កំបោរ ។

កា : តំបន់នេះ គ្រប់គ្រងដោយតាម៉ុក?

ភីន : អឺ! កាលនៅខ្មែរក្រហមតាម៉ុក ។

កា : អ៊ីគិតថា តា ម៉ុក គ្រប់គ្រងម៉េចដែរ?

ភីន : អឺ!តាម៉ុកមនុស្សដូចយើង ខ្មែរដូចយើង មានយួន មានចិនអី ។ តែគាត់ស្លាប់ហើយឥឡូវតា ម៉ុក?

កា : ចា៎!

ភីន : ដែលឃើញដែរ?

កា ៖ អត់ដែលឃើញ ធ្លាប់ឃើញតែ ឌុច មួយ ។

ភីន ៖ ឃើញតែរូបថត ។ គ្រាន់ឃើញតែឌុច?

កា ៖ ចាំ! បើតា ម៉ុក អត់ដឹងមុខម៉េចផង ។

ភីន ៖ តា ម៉ុក គាត់ស ធំ ខ្ពស់ គាត់មនុស្សខ្ពស់១ម៉ែត្រ៧០ ១ម៉ែត្រ៨០តាម៉ុក មើលដូច តា ឌុច នាងឯងដូចអ៊ំនិយាយថា តា ឌុច គាត់ផ្សាយមករឿងតាឌុច គេចោទថាគាត់សម្លាប់មនុស្សច្រើនណាស់ គាត់លែងគិតហើយ គាត់ឲ្យគេសម្លាប់គាត់វិញតើ ហើយម៉េចក៏គេមិនសម្លាប់ ។ គេថាសម្លាប់ម្នាក់នឹងអត់យុត្តិធម៌ ហើយខំចោទគាត់ធ្វើអីចុះបើសម្លាប់អត់យុត្តិធម៌ គាត់មិនឲ្យសម្លាប់ដោយបាញ់គ្រាប់កាំភ្លើងទៀត គាត់ឲ្យសម្លាប់គាត់នឹងគប់ដុំថ្មគប់បានគ្រប់គ្នា អ្នកណាខឹងមកគប់មក បាញ់គ្រាប់កាំភ្លើងតែមួយគ្រាប់ងាប់ហើយ គាត់ឲ្យគប់ ដុំថ្មនៅតែអត់គប់ទៀតនៅមិនយុត្តិធម៌ទៀត រកត្រង់ណាឃើញយុត្តិធម៌ ។ រកអត់ឃើញទេ រកមិនដល់ មិនដឹងត្រង់ណាដល់យុត្តិធម៌ទេ ដល់នយោបាយនាងឯងដឹងថាម៉េច រកអត់ឃើញទេ នយោបាយ ដឹងគេធ្វើម៉េចហៅនយោបាយ រកមិនឃើញ តាមវាមិនទាន់ដែរ ។ ខ្ញុំហូបគុយទាវមុននៅអន្លង់វែង ប៉ុនមិនឃើញនាងឯងទេ គេប្រាប់ខ្ញុំថាឯណាទេ ខ្ញុំចូលហូប គុយទាវ គេថានែក! ពួកដើរសម្ភាសន៍ពួកសាលាក្ដីខ្មែរក្រហម ។

កា ៖ មិនមែនសាលាក្ដីទេ ពួយល់ប្រទ្បាំ ។

ភីន ៖ ហ៉ើ! គេប្រាប់ខ្ញុំចឹងកន្លែងហូបគុយទាវ ខ្ញុំថាឃីសាលាក្ដីសាលាទៅ ខ្ញុំមកហូបគុយទាវ គេហូបម៉េចហូបទៅយើងហូបម៉េចហូប គេថាខ្លាចខ្ញុំនិយាយម៉េចៗប៉ះពាល់គេ ។ ខ្ញុំថាអ!ណាទៅឆ្កួតឆ្កោ ដំបៅដើង ទៅនិយាយរឿងគេ ។

កា ៖ ពួកខ្ញុំមិនមែនមកពីសាលាក្ដីទេ មកពីសកលវិទ្យាល័យភូមិន្ទភ្នំពេញ ។

ប្រពន្ធ ៖ រៀនចប់នៅ?

កា ៖ ខ្ញុំឆ្នាំទី៤ ជិតចប់ហើយ ។

ភីន ៖ យីវី រៀនលឿនមែនទែន គ្រាន់បើ ។

ប្រពន្ធ ៖ ខាងអី?

កា ៖ ខាងប្រព័ន្ធផ្សព្វផ្សាយ ។

ភីន ៖ វាខាងគមនាគមន៍ ខាងទាក់ទងពួកនេះ អាចឹងបានគេឲ្យមកចឹង ដើរធ្វើកម្មសិក្សាចឹង ។ កូនខ្ញុំរៀនភ្នំពេញមួយដែរ ។

កា ៖ រៀននៅ?

ភីន ៖ នៅសាលាន័រតុនៗថ្មី មិនមែនអាចាស់ទេ ។ ហើយគ្នាទៅដេកផ្ទះនៅវិមានឯករាជ្យ ហើយមករៀននៅនឹង ជិះកង់នៅនឹង ។

កា ៖ តែឥឡូវគេរៀបចំធ្វើស្ពានជ្រោយចង្វារមួយទៀតហើយ?

ភីន ៖ ចឹង ធ្វើលើក្រោម ។ ខ្ញុំឮគេផ្សាយថាធ្វើស្ពានច្បារមួយខាងលើ ខាងជើងខាងមកព្រែកព្នៅ

កា ៖ ចា៎! មកពីខាងព្រែកព្នៅ ។

ភីន ៖ អឺ! មកទៅខាងផ្ទះនាងឯង ។

កា ៖ ហ្នឹងហើយធ្វើខាងនឹងមួយ ។

ភីន ៖ ដូចថាឥឡូវវាចង្អៀតណាស់ ស្ពាននឹងគេធ្វើមួយទៀត សម្រាប់ទៅ សម្រាប់មក ។

កា ៖ ចប់បណ្ដោយប្រជាជននាំគ្នាភ័យថាពួកខ្ញុំមកពីណាពីណាវិញ ។

-ជជែកគ្នា-

«ចប់»